# កិច្ចសហប្រតិបត្តិការ
# របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន
# នៅកម្ពុជា

ត្រឹមថ្ងៃទី ០១ ធ្នូ ២០០៦

# មាតិកា


| | |
|---|---|
| ១. គោលនយោបាយសហប្រតិបត្តិការជាមូលដ្ឋាន | ៣ |
| ១.១.ឧស្សាហ៍ៈជាមូលដ្ឋានសំរាប់ការសហប្រតិបត្តិការ | ៣ |
| ១.២.វិស័យជាអាទិភាពសំរាប់សហប្រតិបត្តិការ | ៤ |
| ២. សកម្មភាពសហប្រតិបត្តិការបច្ចុប្បន្ន | ៥ |
| ២.១.ការបញ្ជូនជំនាញការបច្ចេកទេស | ៥ |
| ២.២.កម្មវិធីយុវជនស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេស | ៧ |
| ២.៣.កម្មវិធីអ្នកស្ម័គ្រចិត្តកំរិតខ្ពស់ | ៩ |
| ២.៤.កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស | ១១ |
| ២.៥.កម្មវិធីឧស្សាហ៍ៈកិច្ចសិក្សារបស់យុវជន | ១២ |
| ២.៦.គំរោងសហប្រតិបត្តិការបច្ចេកទេស | ១៤ |
| ២.៧.ការផ្តល់សំភារៈចាំបាច់ | ២២ |
| ២.៨.ការសិក្សាអភិវឌ្ឍន៍ | ២៣ |
| ២.៩.គំរោងជំនួយឥតសំណង | ២៨ |
| ២.១០.កម្មវិធីលើកកំពស់សហគមន៍ | ៣៥ |
| ២.១១.កម្មវិធីភាពជាដៃគូរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | ៣៦ |
| ២.១២.ស្ថិតិមូលដ្ឋានរបស់កម្ពុជា | ៣៨ |

## ១. គោលនយោបាយជាមូលដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការ

### ១.១. ទស្សនៈទានជាមូលដ្ឋាន

នៅក្នុងកំឡុងទសវត្សកន្លងមកនេះ ប្រទេសជប៉ុនដែលធ្លាប់ជាប្រទេសមួយមានចំណែកយ៉ាងសំខាន់ ក្នុងការជួយជ្រោមជ្រែងដល់ដំណើរការសន្តិភាពនៅកម្ពុជារហូតដល់បានសំរេច បានផ្តល់ជំនួយអភិវឌ្ឍន៏ជាផ្លូវការ មានទំហំយ៉ាងច្រើនដល់កម្ពុជា ។ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានដំណើរការសកម្មភាពរបស់ខ្លួនផ្អែកលើឯកសារគោលសំខាន់៧មួយចំនួនមានដូចជា – **ធម្មនុញ្ញស្តីអំពីជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន** (Japan’s ODA Charter) **គោលនយោបាយរយៈពេលមធ្យមសំរាប់ជំនួយអភិវឌ្ឍន៍ផ្លូវការ** (ODA Mid-term Policy) និង **គោលនយោបាយជំនួយប្រចាំប្រទេសសំរាប់កម្ពុជា** ។ ទីភ្នាក់ងារបានប្រើប្រាស់ផងដែរនូវគោលគំនិតគោលនយោបាយ និង យុទ្ធសាស្រ្តអភិវឌ្ឍន៏របស់កម្ពុជាសំរាប់ជាមធ្យោបាយបង្ហាញផ្លូវជំនួយរបស់ខ្លួន ។ ក្នុងកិច្ចសហប្រតិបត្តិការជាមួយភាគីកម្ពុជា ទីភ្នាក់ងារ មានទិសដៅ **ធានាសំរេចអោយបាននូវសុវត្ថិភាពក្នុងការរស់នៅនៃមនុស្សជាតិ តាមរយៈការចូលរួមចំណែកក្នុងការធ្វើអោយមានកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដោយប្រើប្រាស់ ការអភិវឌ្ឍន៍ធនធានមនុស្ស ការស្ថាបនាសមត្ថភាពស្ថាប័ន និង ការពង្រឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាមធ្យោបាយដ៏សំខាន់** ។ ចំនុចខាងក្រោមបានត្រូវឆ្លុះបញ្ចាំងនៅក្នុងការផ្តួចផ្តើម ការបង្កើត និង ការអនុវត្តន៏ គំរោងការអភិវឌ្ឍន៏របស់ជប៉ុន ។ ក្រៅពីនោះ គោលគំនិតដទៃទៀតដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ (CG) កិច្ចពិភាក្សាពីគោលនយោបាយអភិវឌ្ឍន៏កម្ពុជា-ជប៉ុន (Policy Dialogue) និង ទស្សនៈដែល បានបង្ហាញនៅក្នុងឱកាសដទៃទៀត សុទ្ធតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការអនុវត្តន៏ជាក់ស្តែងនៃជំនួយអភិវឌ្ឍន៏ជាផ្លូវការរបស់ជប៉ុនផងដែរ ។

**ក.** ការអភិវឌ្ឍន៏ធនធានមនុស្ស និង ស្ថាប័ន ដែលរួមចំណែកដល់ការពង្រឹងនិតិរដ្ឋ មុខងាររដ្ឋបាល សន្តិសុខ សាធារណៈ ស្ថេរភាពនៃការរស់នៅរបស់ប្រជាជន និង ការពង្រឹងវិស័យហិរញ្ញវត្ថុសាធារណៈ គឺជាកត្តាដ៏សំខាន់ ដើម្បីជំរុញបន្ថែមទៀតដល់កិច្ចប្រឹងប្រែងក្នុងការស្តារឡើងវិញ និង ការធ្វើកំណែទំរង់នៅគ្រប់វិស័យដែលកម្ពុជាកំពុងធ្វើ និង នឹងធ្វើ ។

**ខ.** កំនើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៏ឧស្សាហកម្មតាមរយៈការអភិវឌ្ឍន៏តំបន់សេដ្ឋកិច្ចជាក់លាក់ដែលប្រកបដោយចីរភាព ការពង្រឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍន៏វិស័យឯកជន ជាកត្តាចាំបាច់ ក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈកំនើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៏តំបន់ក្នុងបរិបទអាស៊ាន និង អាងទន្លេ មេគង្គ។

**គ.** ការកាត់បន្ថយគំលាតខុសគ្នានៃជីវភាពរបស់ប្រជាជន ការស្ថាបនាមូលដ្ឋានសេដ្ឋកិច្ចដ៏រឹងមាំមួយ និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ជាកត្តាដែលត្រូវយកចិត្តទុកដាក់ក្នុងដំណើរការនៃការអភិវឌ្ឍន៏ ។ ទន្ទឹមនឹងនេះ ការជំរុញសកម្មភាពកសិកម្ម ការលើកកំពស់ស្ថានភាពរស់នៅរបស់ប្រជាជននៅតាមជនបទ និង ការគ្រប់គ្រងធនធានធម្មជាតិ គឺជាកត្តាគន្លឹះរួមចំណែកដ៏សំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ ។

ឃ-ការអភិវឌ្ឍន៍ធនធានមនុស្សដោយគាំទ្រដល់ការអភិវឌ្ឍន៍សង្គមមួយដែលមានកំនើនសេដ្ឋកិច្ចសំរាប់រយៈពេលវែង ជាការចាំបាច់ ។ ដូច្នេះលទ្ធភាពនៃការទទួលបានសេវាអប់រំ សេវាសុខាភិបាលដែលប្រកបដោយគុណភាព បរិស្ថានរស់នៅប្រកបដោយសុខមាលភាពរបស់ទីក្រុង និង ការចូលរួមឡើងវិញពីក្រុមងាយរងគ្រោះរបស់សង្គម នៅក្នុងដំណើរការអភិវឌ្ឍន៍ ត្រូវតែពង្រឹងក្នុងកំរិតមួយសមស្រប ។

ង-ទោះបីជាយ៉ាងណាក៏ដោយ បើការអភិវឌ្ឍន៍ពុំមានការការដឹកនាំ និង ម្ចាស់ការ ដោយរាជរដ្ឋាភិបាលកម្ពុជា ការអភិវឌ្ឍន៍នោះនឹងមិនមានស្ថេរភាពឡើយ ។ ហេតុនេះ គ្រប់សកម្មភាពរបស់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ជប៉ុន ត្រូវតែធ្វើឡើងដោយឈរលើការពិភាក្សាជាមួយរដ្ឋាភិបាល ការទទួលខុសត្រូវ និង តំលាភាពទៅវិញទៅមក ក្នុងស្មារតីអភិវឌ្ឍន៍សមត្ថភាពជាតិកម្ពុជា ។

## ១-២- វិស័យជាអត្ថិភាពសំរាប់កិច្ចសហប្រតិបត្តិការ

ការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិជប៉ុនប្រចាំកម្ពុជា បានធ្វើការត្រួតពិនិត្យ និង កែសំរួលឡើងវិញនូវ **កម្មវិធីប្រចាំប្រទេស** (Country Assistance Program) របស់ខ្លួននៅឆ្នាំ ២០០៥ ផ្អែកលើ **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាលអាណត្តិទី៣ និង សូចនាករសំរាប់ការត្រួតពិនិត្យរួមគ្នា (Joint Monitoring Indicators) ដែលបានអនុម័តក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ ។ កម្មវិធីជំនួយប្រចាំប្រទេសបានដាក់ចេញជាបន្ទូវវិស័យជាអត្ថិភាពចំនួន ៥ ដែលមានកម្មវិធីសហប្រតិបត្តិការចំនួន ២៥ ដូចខាងក្រោម :

| អាទិភាពសំរាប់កិច្ចសហប្រតិបត្តិការ | កម្មវិធីសំរាប់សហប្រតិបត្តិការ |
|---|---|
| ការជំរុញអភិបាលកិច្ចល្អ | កម្មវិធីអភិវឌ្ឍន៍ច្បាប់ជាមូលដ្ឋាន<br>កម្មវិធីលើកកំពស់សមត្ថភាពរដ្ឋបាល<br>កម្មវិធីពង្រឹងស្ថិតិជាតិ<br>កម្មវិធីកាត់រំសាយកងទ័ព<br>កម្មវិធីតំរង់ទិសយេនឌ័រ<br>កម្មវិធីពង្រឹងសន្តិសុខសាធារណៈ<br>កម្មវិធីពង្រឹងសកម្មភាពកំចាត់មីន និង<br>កម្មវិធីគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ |
| កំនើនសេដ្ឋកិច្ច និង ឧស្សាហកម្ម | កម្មវិធីទ្រទ្រង់ដល់ការបង្កើតផែនការ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់តំបន់សេដ្ឋកិច្ចជាក់លាក់<br>កម្មវិធីលើកកំពស់ប្រព័ន្ធដឹកជញ្ជូន |

| | |
|---|---|
| | កម្មវិធីពង្រឹងប្រព័ន្ធផលិត បញ្ជូន និង ចែកចាយថាមពលអគ្គិសនី<br>កម្មវិធីពង្រឹងប្រព័ន្ធទូរគមនាគមន៍ និង ប្រព័ន្ធផ្សព្វផ្សាយ<br>កម្មវិធីអភិវឌ្ឍន៍វិស័យឯកជន |
| ការអភិវឌ្ឍន៍ជនបទ និង កសិកម្ម | កម្មវិធីលើកកំពស់កសិកម្មដែលប្រើប្រាស់ប្រព័ន្ធ ធារាសាស្ត្រ និង ប្រព័ន្ធកសិដ្ឋាន<br>កម្មវិធីលើកកំពស់ប្រព័ន្ធចែកចាយផលិតផលកសិកម្ម<br>កម្មវិធីអភិវឌ្ឍន៍តំបន់ដាច់ស្រយាល<br>កម្មវិធីស្ថាបនាសមត្ថភាពវិស័យគ្រប់គ្រងព្រៃឈើ<br>កម្មវិធីការពារ និង ប្រើប្រាស់ប្រកបដោយចេរភាពនូវធនធានជលផល |
| ការអភិវឌ្ឍន៍សង្គម | កម្មវិធីលើកកំពស់គុណភាព និង លទ្ធភាពទទួលបានការអប់រំ<br>កម្មវិធីលើកកំពស់ការអប់រំផ្នែកវិទ្យាសាស្ត្រ និង គណិតសាស្ត្រ<br>កម្មវិធីសំដៅសំរេចគោលដៅសហសវត្ស<br>កម្មវិធីពង្រឹងសេវាថែទាំសុខភាព<br>កម្មវិធីលើកកំពស់បរិយាកាសរស់នៅតំបន់ទីក្រុង<br>កម្មវិធីជំរុញការចូលរួមក្នុងសង្គមរបស់ជនពិការ និង ជនអសមត្ថភាព |
| បញ្ហាអន្តរវិស័យខាងអត្ថិភាព | ការគ្រប់គ្រង និង សំរបសំរួលជំនួយ |

## ២.សកម្មភាពសហប្រតិបត្តិការក្នុងពេលបច្ចុប្បន្ន

### ២.១. ការបញ្ជូនជំនាញការបច្ចេកទេស

ការបញ្ជូនជំនាញការបច្ចេកទេសរួមចំណែកជាច្រើននៅក្នុងការអភិវឌ្ឍន៍ ដូចជា ក្នុងការកសាងសមត្ថភាពទាំងនៅថ្នាក់ជាតិ និង តាមវិស័យ ការបង្កើតអោយមានស្ថាប័ន និង អង្គការគ្រប់គ្រង ការជួយខ្លួនឯងសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និង ការអភិវឌ្ឍន៍ប្រកបដោយចេរភាពនៅក្នុងប្រទេសទាំងនោះ ។ បច្ចុប្បន្នមានជំនាញការជប៉ុនចំនួន ៥៩ នាក់ ( ក្នុងនោះ ៣៨ នាក់បំរើការរយៈពេលវែងលើសពី ១ឆ្នាំ និង ២១ នាក់ រយៈពេលខ្លីតិចជាង ១ឆ្នាំ ) ត្រូវបានបញ្ជូន និង កំពុងធ្វើការនៅតាម ស្ថាប័ន និង ក្រសួងនានារបស់រដ្ឋាភិបាល ដូចខាងក្រោម :

<...> ជំនាញការដែលបញ្ជូនតាមរយៈគំរោងកិច្ចសហប្រតិបត្តិការបច្ចេកទេស

.......ជំនាញការបញ្ជូនដោយលែកពុំមានទាក់ទងនឹងគំរោងសហប្រតិបត្តិការបច្ចេកទេស

# ជំនាញការរយៈពេលវែង (ត្រឹមថ្ងៃទី ០១ ធ្នូ ២០០៦)

| ក្រសួង/ស្ថាប័នដែលពាក់ព័ន្ធ | ចំនួន | គំរោង/ជំនាញ |
|---|---|---|
| ក្រសួងសុខាភិបាល | ៣ | <គំរោងជំរុញការគ្រប់គ្រងសំភារៈបរិក្ខាពេទ្យ> (1) |
| | | |
| | | <គំរោងអភិវឌ្ឍន៍ធនធានមនុស្សវិស័យសហវេជ្ជសាស្ត្រ> (2) |
| ក្រសួងធនធានទឹក និង ឧត្តុនិយម | ៥ | <គំរោងមជ្ឈមណ្ឌលបច្ចេកទេសសំរាប់ប្រព័ន្ធធារាសាស្ត្រដំណាក់កាលទី២> (3) |
| | | អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកសំរាប់វិស័យកសិកម្ម (1) |
| | | Synoptic Meteorology (1) |
| ក្រសួងអប់រំ យុវជន និង កីឡា | ៥ | <មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន>(4) |
| | | អ្នកសំរបសំរួលកម្មវិធីសំរាប់វិស័យអប់រំ (1) |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង ជលផល | ៥ | ទីប្រឹក្សាផ្នែកគោលនយោបាយ និង រដ្ឋបាលព្រៃឈើ (1) |
| | | <គំរោងកសាងសមត្ថភាពវិស័យព្រៃឈើដំណាក់កាលទី២>(3) |
| | | ទីប្រឹក្សាផែនការគោលនយោបាយកសិកម្ម (1) |
| ក្រសួងសាធារណៈការ និង ដឹកជញ្ជូន | ៣ | ទីប្រឹក្សាសាធារណៈការ និង ដឹកជញ្ជូន (1) |
| | | ទីប្រឹក្សាផ្នែកផ្លូវថ្នល់ (1) |
| | | ទីប្រឹក្សាគ្រប់គ្រង និង ដំណើរការកំពង់ផែ (1) |
| អាជ្ញាធរជាតិកំចាត់មីនកម្ពុជា CMAC | ២ | ទីប្រឹក្សាបច្ចេកទេស ទ្រទ្រង់ និង ដឹកជញ្ជូន (1) |
| | | ប្រធានគ្រប់គ្រងទីប្រឹក្សាផ្នែកស្ថាប័ន (1) |
| ក្រសួងយុត្តិធម៌ | ២ | <គំរោងលើកកំពស់ប្រព័ន្ធច្បាប់ និង តុលាការ ដំណាក់កាលទី២>(2) |
| ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ៣ | <គំរោងកសាងសមត្ថភាព និង ពង្រឹងស្ថាប័នវិស័យអគ្គិសនី> (3) |
| ក្រសួងកិច្ចការនារី | ២ | <គំរោងស្តីពីការបញ្ជ្រាប និង ការអភិវឌ្ឍន៍គោលនយោបាយយេនឌ័រតាមរយៈការពង្រឹងសមត្ថភាពផ្នែកព័ត៌មាន និង ស្រាវជ្រាវ > (2) |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) | ១ | គ្រប់គ្រង និង សំរបសំរួលជំនួយអភិវឌ្ឍន៍ (1) |
| ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ | <គំរោងគ្រប់គ្រងហិរិភ័យផ្នែកពន្ធដា>(1) |
| ក្រុមប្រឹក្សាកាត់បន្ថយកងកំលាំងប្រដាប់អាវុធ-ទីស្តីការគណរដ្ឋមន្ត្រី | ១ | អ្នកសំរបសំរួលកម្មវិធីសំរាប់ទ្រទ្រង់ការកាត់រំសាយកងទ័ព (1) |
| ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ១ | ទីប្រឹក្សាអភិវឌ្ឍន៍បណ្តាញទូរគមនាគមន៍ (1) |
| ក្រសួងព័ត៌មាន | ១ | ទីប្រឹក្សាព័ត៌មាន និង រៀបចំឯកសារ (1) |
| ក្រសួងពាណិជ្ជកម្ម | ១ | ទីប្រឹក្សាផ្នែកពាណិជ្ជកម្ម (1) |
| រាជបណ្ឌិតសភាវិជ្ជាជីវចៅក្រម និងរាជអាជ្ញា | ២ | <គំរោងពង្រឹងការបណ្តុះបណ្តាលផ្នែករដ្ឋប្បវេណីយនៅរាជបណ្ឌិតសភាវិជ្ជាជីវចៅក្រម និងរាជអាជ្ញា> (2) |
| អគ្គលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១ | <គំរោងស្តារឡើងវិញជាបន្ទាន់ និង ពង្រឹងឧត្តុនិយមសំរាប់អាកាសចរស៊ីវិល>(1) |
| សរុប | ៣៨ | |

**ជំនាញការរយៈពេលខ្លី (ត្រឹមថ្ងៃទី ០១ ធ្នូ ២០០៦)**

| ក្រសួងពាក់ព័ន្ធ | ចំនួន | គំរោង/ជំនាញ |
|---|---|---|
| ក្រសួងសុខាភិបាល | ៦ | <គំរោងអភិវឌ្ឍន៍ធនធានមនុស្សវិស័យសហវេជ្ជសាស្ត្រ> (2) |
| | | |
| | | <គំរោងគ្រប់គ្រងជំងឺរបេងដំណាក់កាលទី២> (4) |
| ក្រសួងអប់រំ យុវជន និង កិឡា | ៣ | <មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន> (3) |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ៥ | <គំរោងពង្រឹង និង ពង្រីកវារីវប្បកម្មទឹកសាបនៅកម្ពុជា> (3) |
| | | <គំរោងកសាងសមត្ថភាពវិស័យព្រៃឈើដំណាក់កាលទី២> (1) |
| | | <គំរោងពង្រឹង និង អភិវឌ្ឍន៍តំបន់ជនបទនៅបាត់ដំបង> (1) |
| | | |
| ក្រសួងធនធានទឹក និងឧត្តុនិយម | ៣ | <គំរោងមជ្ឈមណ្ឌលបច្ចេកទេសសំរាប់ប្រព័ន្ធធារាសាស្ត្រដំណាក់កាលទី២> (1) |
| | | ទីប្រឹក្សាបច្ចេកទេសសំរាប់កសាងអនុក្រិតអំពីច្បាប់ក្នុងការគ្រប់គ្រងធនធានទឹក (2) |
| វិទ្យាស្ថានជាតិស្ថិតិកម្ពុជា | ២ | <គំរោងពង្រឹងសមត្ថភាពស្ថិតិផ្លូវការនៅកម្ពុជា> (1) |
| ក្រសួងកិច្ចការនារី | ១ | <គំរោងស្តីពីការបញ្ជ្រាប និង ការអភិវឌ្ឍន៍គោលនយោបាយយេនឌ័រតាមរយៈការពង្រឹងសមត្ថភាពផ្នែកព័តមាន និង ស្រាវជ្រាវ > (1) |
| ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ | <គំរោងគ្រប់គ្រងហិរិភ័យផ្នែកពន្ធដា>(1) |
| ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ១ | <គំរោងកសាងសមត្ថភាព និង ពង្រឹងស្ថាប័នវិស័យអគ្គិសនី> (1) |
| សរុប | ២១ | |

## ២.២.កម្មវិធីយុវជនស្ម័គ្រចិត្តជប៉ុនដើម្បីកិច្ចសហប្រតិបត្តិការក្រៅប្រទេស (JOCV)

កម្មវិធីយុវជនស្ម័គ្រចិត្ត មានគោលបំណងជួយ និង ជំរុញសកម្មភាពរបស់អ្នកស្ម័គ្រចិត្តជប៉ុន ដែលមានអាយុចាប់ពី ២០-៣៩ ឆ្នាំ ក្នុងកិច្ចសហប្រតិបត្តិការក្រៅប្រទេស និង រួមចំណែកក្នុងការសហការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដោយផ្អែកលើការស្នើសុំដែលទទួលបានពីប្រទេសទាំងនោះ ។ នៅកម្ពុជា សមាជិកយុវជនស្ម័គ្រចិត្តជប៉ុន បានចូលមកតាំងពីឆ្នាំ ១៩៦៦ ។ តែជាអកុសល្យ កម្មវិធីនេះត្រូវបានដកចេញពីប្រទេសកម្ពុជា នៅក្នុងទស្សវត្សន៍ឆ្នាំ ១៩៧០ ដោយមកពីមានស្ថានភាពនយោបាយតឹងតែង និង ភាពវឹកវរនៅក្នុងប្រទេស ហើយដែលក្រោយមកកម្មវិធីនេះត្រឡប់ចូលមកកាន់ប្រទេសកម្ពុជាម្តងទៀតនៅឆ្នាំ១៩៩២ ។ តារាងខាងក្រោមបង្ហាញពីក្រុមអ្នកស្ម័គ្រចិត្ត និង ស្ថាប័នដែលពួកគេកំពុងធ្វើការជាមួយ :

| ក្រសួង/ស្ថាប័ណ្ណពាក់ព័ន្ធ | ជំនាញ | ចំនួន | កន្លែងប្រចាំការ |
|---|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | គ្រូបង្រៀនភាសាជប៉ុន | ៥ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (1) |
| | | | សាកលវិទ្យាល័យជាតិគ្រប់គ្រង (2) |
| | | | សាកលវិទ្យាល័យច្បាប់ និង សេដ្ឋកិច្ច (2) |
| | គ្រូសាលាមត្តេយ្យ | ៣ | មត្តេយ្យកុមារថ្មី (ស្វាយរៀង) (1) |
| | | | មត្តេយ្យអង្គរ (សៀមរាប) (1) |
| | | | មន្ទីរអប់រំ យុវជន កីឡាខេត្តបាត់ដំបង (1) |
| | គ្រូបឋមសិក្សា | ៦ | សាលាបឋមសិក្សាសាគូរ៉ា (ក្រុងព្រះសីហនុ) (1) |
| | | | សាលាបឋមសិក្សាឧត្តរ (កំពង់ចាម) (1) |
| | | | សាលាបឋមសិក្សា ២ធ្នូ (បាត់ដំបង) (1) |
| | | | សាលាបឋមសិក្សាវត្តកំពេញ (បាត់ដំបង) (1) |
| | | | សាលាបឋមសិក្សាជាស៊ីម ខេត្តបាត់ដំបង (1) |
| | | | សាលាបឋមសិក្សាផ្សារលើ ក្រុងព្រះស៊ីហនុ (1) |
| | គ្រូអប់រំកាយ | ៤ | អនុវិទ្យាល័យព្រះឥន្ទកោសា (សៀមរាប) (1) |
| | | | មជ្ឈមណ្ឌលគរុកោសល្យខេត្ត (ក្រុងព្រះសីហនុ) (1) |
| | | | មជ្ឈមណ្ឌលគរុកោសល្យខេត្ត (ក្រចេះ) (1) |
| | | | សាលាមធ្យមសិក្សាអប់រំកាយ និង កីឡា (1) |
| | គ្រូពិសោធន៍វិទ្យាសាស្ត្រ និង គណិតសាស្ត្រ | ៣ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ/តាកែវ (1) |
| | | | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តបាត់ដំបង (1) |
| | | | មជ្ឈមណ្ឌលគរុកោសល្យ ក្រុងភ្នំពេញ (1) |
| | អៃគីដូ | ១ | គណៈកម្មការកីឡាការពារខ្លួន (1) |
| | សកម្មភាពយុវជន | ១ | នាយកដ្ឋានអប់រំ យុវជន និង កីឡា(1) |
| | គ្រូកុំព្យូទ័រ | ១ | សាលាគរុកោសល្យខេត្តក្រចេះ (1) |
| អាជ្ញាធរអប្សរា | ផ្នែកពត៌មានវិទ្យា | ១ | អាជ្ញាធរអប្សរា (សៀមរាប) (1) |
| ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | គ្រូកាត់ដេរ | ១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត (1) |
| | គ្រូផ្នែកព័តមានវិទ្យា | ១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង (1) |
| ក្រសួងព័ត៌មាន | ផ្នែកផ្សព្វផ្សាយ | ១ | មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (1) |
| ក្រសួងសុខាភិបាល | ផ្នែកបន្ទប់ពិសោធ | ១ | មន្ទីរពេទ្យបង្អែកក្រុងបាត់ដំបង (1) |
| | ផ្នែកគិលានុបដ្ឋាយិកា | ១ | មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក |
| ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ការងារផ្នែកបណ្តាញខ្សែទូរស័ព្ទ | ១ | នាយកដ្ឋានទូរគមនាគមន៍ក្នុងស្រុក/មជ្ឈមណ្ឌលទូរសព្ទ័អង្គរ (1) |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | គ្រូបង្រៀនកុំព្យូទ័រ | ១ | សាលាជាតិកសិកម្មកំពង់ចាម (1) |
| | អ្នកវិភាគឈាមនិងរោគសញ្ញាក្នុងសាច់ | ១ | នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល (1) |
| ក្រសួងផែនការ | ស្ថិតិសេដ្ឋកិច្ច | ១ | វិទ្យាស្ថានជាតិស្ថិតិ (1) |
| | សរុប | ៣៤ | |

## ២.៣.កម្មវិធីអ្នកស្ម័គ្រចិត្តកំរិតខ្ពស់ (Senior Volunteer)

ក្នុងការឆ្លើយតបទៅនឹងតំរូវការជំនួយបច្ចេកទេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលចេះតែកើនឡើងទាំងប្រភេទ និង ចំនួន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនបានចាប់ផ្តើមបញ្ជូនអ្នកស្ម័គ្រចិត្តកំរិតខ្ពស់របស់ខ្លួន នៅឆ្នាំ ១៩៩០ ។ គោលបំណងសំខាន់របស់កម្មវិធីនេះ គឺជួយដល់អ្នកស្ម័គ្រចិត្តទាំងនោះ យ៉ាងពេញទំហឹងក្នុងការងារកសាង និង អភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ អ្នកស្ម័គ្រចិត្តកំរិតខ្ពស់មានអាយុចាប់ពី ៤០ ដល់ ៦៩ ឆ្នាំ និងជាបុគ្គលដែលមានឆន្ទៈមុតស្រួចក្នុងការធ្វើការជារបៀបស្ម័គ្រចិត្ត ជាមួយនឹងចំណេះដឹង/បទពិសោធន៍ទូលំទូលាយរបស់ពួកគាត់លើវិស័យជាច្រើន ។ នៅកម្ពុជា កម្មវិធីបានចាប់ផ្តើមបញ្ជូនអ្នកស្ម័គ្រចិត្តនៅខែមេសា ឆ្នាំ ២០០១ ។ ខាងក្រោមជាពត៌មានអំពីអ្នកស្ម័គ្រចិត្តដែលកំពុងធ្វើការនៅស្ថាប័នរបស់កម្ពុជា

| ក្រសួង /ស្ថាប័នពាក់ព័ន្ធ | ជំនាញ | ចំនួន | ស្ថាប័នប្រចាំការ |
|---|---|---|---|
| ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | វិស្វករផ្នែកប្រព័ន្ធ | ១ | វិជ្ជាស្ថានបណ្តុះបណ្តាលពហុវិជ្ជាជីវៈ កុសុមៈ (1) |
| | ជុសជុលវិទ្យុ-ទូរទស្សន៍ (អេឡិកត្រូនិក) | ១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងបាត់ដំបង (4) |
| | ជុសជុលរថយន្ត | ១ | |
| | ផ្នែករចនាប្លង់ដោយកុំព្យូទ័រ | ១ | |
| | ផ្នែកឧបករណ៍អេឡិកត្រូនិក | ១ | |
| | ជុសជុលរថយន្ត | ២ | សាលាមធ្យមសិក្សាឧស្សាហកម្មឫស្សីកែវ (2) |
| | ផ្នែកបរិក្ខាម៉ាស៊ីនត្រជាក់ | | |
| ក្រសួងអប់រំ យុវជន និង កីឡា | គ្រូការ៉ាតេ (Karate) | ១ | សហព័ន្ធការ៉ាតេដូកម្ពុជា (1) |
| | បណ្ណារក្ស | ១ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (1) |
| | អប់រំមត្តេយ្យសិក្សា | ១ | សាលាគរុកោសល្យមតេយ្យមជ្ឈឹម (1) |
| | យូដូ (Judo) | ១ | នាយកដ្ឋានអប់រំ យុវជន និង កីឡា (1) |
| | គ្រូអប់រំកាយ និង កីឡា | ១ | សាលាបឋមសិក្សាទួលសំបូរ (1) |
| | សកម្មភាពយុវជន | ១ | សមាគមន៍ជាតិ |
| ក្រសួងបរិស្ថាន | អ្នកអភិរក្សបរិស្ថានធម្មជាតិ | ១ | ឧទ្យានជាតិរាម.ក្រុងព្រះសីហនុ (1) |
| អាជ្ញាធរអប្សរា | ផ្នែករៀបចំក្រុង | ១ | នាយកដ្ឋានអភិវឌ្ឍន៍ក្រុង (1) |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | មីក្រូជីវវិទ្យា | ១ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម (1) |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រព័ន្ធរដ្ឋបាល | ១ | មជ្ឈមណ្ឌលស្រាវជ្រាវសាធារណការ (1) |
| សាលាខេត្តសៀមរាប | ផែនការវិស័យអប់រំ | ១ | ការិយាល័យអប់រំ យុវជន និងកីឡា ខេត្ត (1) |
| សាលាក្រុងភ្នំពេញ | ផែនការអប់រំ | ១ | ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង (1) |
| ក្រសួងសុខាភិបាល | គ្រប់គ្រងគិលានុបដ្ឋាយិការ | ១ | មន្ទីរពេទ្យកុមារជាតិ (1) |
| ក្រសួងសង្គមកិច្ច | គ្រូមតេយ្យ | ១ | សមាគមន៍ជនឥតទីពឹង (1) |
| ក្រសួងទេសចរណ៍ | ពង្រឹងទេសចរ | ១ | ក្រសួងទេសចរណ៍ (1) |
| សរុប | | ២២ | |

## របាយអ្នកស្ម័គ្រចិត្តរបស់ជប៉ុនដែលកំពុងបំរើការនៅប្រទេសកម្ពុជា (គិតត្រឹមថ្ងៃទី ០១ ធ្នូ ២០០៦)




**JOCV: 34**
**SV: 22**

## ២.៤.កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស

គោលបំណងនៃកម្មវិធីនេះគឺធ្វើអោយ អ្នកជំនាញ អ្នកស្រាវជ្រាវ និង អ្នករដ្ឋបាល មកពីប្រទេសកំពុងអភិវឌ្ឍន៍ ទទួលបានការបណ្តុះបណ្តានៅ ប្រទេសជប៉ុន រឺ នៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតដើម្បីអោយពួកគេទាំងនោះទទួលបាននូវចំណេះដឹង និង ជំនាញដែលត្រូវការចាំបាច់សំរាប់ការអភិវឌ្ឍន៍ប្រទេសរបស់ពួកគេ ។ ជំនាញសំរាប់ការបណ្តុះបណ្តាគ្របដណ្តប់យ៉ាងទូលំទូលាយរាប់ចាប់ពីផ្នែករដ្ឋបាលជំនួញ ការគ្រប់គ្រង គុណភាព អភិរក្សបរិស្ថាន និង វិស្វកម្មសំណង់ ។

**. ការបណ្តុះបណ្តាលនៅជប៉ុន**

រវាងឆ្នាំ ១៩៨៩ ដល់ ឆ្នាំ២០០៥ មានសិក្ខាកាមចំនួន ១៩៨១ ។ ស្ថិតិខាងក្រោមជាស្ថិតិពីខែមេសា-ធ្នូ ២០០៦ ។

【ការបណ្តុះបណ្តាលនៅប្រទេសជប៉ុន (ឆ្នាំសារពើពន្ធ២០០៥)】

| វគ្គ | ចំនួនអ្នកចូលរួម |
|---|---|
| បណ្តុះបណ្តាជាក្រុម | ៥៨ |
| បណ្តុះបណ្តាផ្អែកលើតំរូវការរបស់ប្រទេស រឺតំបន់ | ៣៤ |
| បណ្តុះបណ្តាសំរាប់សមភាគី<br>Counter-part Training | ៣២ |
| បណ្តុះបណ្តារយ:ពេលវែង | ៧ |
| 【សរុប】 | ១៣១ |

**. ការបណ្តុះបណ្តានៅប្រទេសកំពុងអភិវឌ្ឍន៍ (មេសា.ធ្នូ ២០០៦)**

【ការបណ្តុះបណ្តានៅប្រទេសកំពុងអភិវឌ្ឍន៍】

| ប្រទេសផ្តល់ការសិក្សា | ចំនួន | មុខវិជ្ជា |
|---|---|---|
| ម៉ាឡេស៊ី | ២០ | ៤ |
| ឥណ្ឌូណេស៊ី | ១០ | ៤ |
| ហ្វីលីពីន | ២០ | ៥ |
| សាំងហ្គាពួរ | ៧០ | ១២ |
| សេរីលាំងការ | ២ | ២ |
| ថៃឡង់គ៍ | ២៦ | ៥ |
| 【សរុប】 | ១៤៨ | ៣២ |

~ ការបណ្តុះបណ្តាលនៅប្រទេសកំពុងអភិវឌ្ឍន៍ធ្វើនៅកម្ពុជា

【ការបណ្តុះបណ្តាដោយប្រទេសកំពុងអភិវឌ្ឍន៍ដែលធ្វើនៅកម្ពុជា (២០០១)】

| សិក្ខាសាលា | ទីកន្លែង | ចំនួនសិក្ខាកាម |
|---|---|---|
| សិក្ខាសាលាអំពីការពង្រឹងសមត្ថភាពសំរាប់ជនអសមត្ថភាព | ក្នុងស្រុក | ៣០ |
| | ក្រៅប្រទេស | ២៣ |
| | 【សរុប】 | ៥៣ |

## ២.៥.កម្មវិធីទស្សនកិច្ចសិក្សារបស់យុវវ័យប្រទេសកំពុងអភិវឌ្ឍន៍

【រយៈពេល ៥ ឆ្នាំដំបូងនៃកម្មវិធី】

*(ពីឆ្នាំសារពើពន្ធជប៉ុន ១៩៩៥ ដល់ ១៩៩៩ ចំនួន ៣០ នាក់/ឆ្នាំ)*

| រយៈពេល | វិស័យ | ចំនួន |
|---|---|---|
| ១៩៩៥-១៩៩៧ | អប់រំ | ៩០ |
| ១៩៩៨-១៩៩៩ | សេដ្ឋកិច្ច | ៦០ |
| | 【សរុប】 | **១៥០** |

កម្មវិធីទស្សនកិច្ចសិក្សារបស់យុវវ័យប្រទេសកំពុងអភិវឌ្ឍន៍ គឺជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ។ តាមរយៈកម្មវិធីនេះ យុវវ័យដែលមានការទទួលខុសត្រូវ ក្នុងការកំនត់ជោគវាសនារបស់ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានបញ្ជូនទៅជប៉ុនសំរាប់ទស្សនកិច្ចសិក្សារយៈពេលមួយខែ តាមមុខជំនាញនីមួយៗរបស់ពួកគេ ។ នៅប្រទេសជប៉ុន ពួកគេសិក្សាអំពីស្ថានភាពបច្ចុប្បន្នរបស់ជប៉ុន និង ជួបជាមួយយុវវ័យជប៉ុនដែលមានអាយុប្រហាក់ប្រហែលគ្នា និង មានជំនាញស្រដៀងគ្នា ។

【ក្រោយឆ្នាំសារពើពន្ធ ២០០១ 】

| ឆ្នាំ | ចំនួនអ្នកចូលរួមសរុប | មុខវិជ្ជា | | | |
|---|---|---|---|---|---|
| | | កម្មវិធីសំរាប់តែកម្ពុជា | | កម្មវិធីជាមួយនឹងប្រទេសអាស៊ាន | |
| | | វិស័យ | ចំនួន | វិស័យ | ចំនួន |
| ២០០០ | ៤០ | កសិកម្ម (ការដឹកជញ្ជូនផលិតផលឧស្សាហកម្ម) | ១៥ | អប់រំ | ២ |
| | | | | សេដ្ឋកិច្ច | ២ |
| | | មន្ត្រីរាជការ(កំនែទំរង់រដ្ឋបាល) | ១៥ | សេវាថែទាំសុខភាព | ២ |
| | | | | សុខមាលភាពសង្គម | ២ |
| | | | | ជីវសាស្ត្រ | ២ |
| | | កសិកម្ម (ការអភិវឌ្ឍន៍ជនបទ) | ១៥ | អប់រំ | ២ |
| | | | | សេដ្ឋកិច្ច | ២ |
| | | | | សេវាសុខភាព | ២ |
| | | | | សុខមាលភាពសង្គម | ២ |

| | | | | | |
|---|---|---|---|---|---|
| | | | | ជីវសាស្ត្រ | ២ |
| ២០០២ | ៤០ | កសិកម្ម (ការបែងចែកផលិតផលកសិកម្ម) | ១៥ | អប់រំ | ២ |
| | | | | សេដ្ឋកិច្ច | ២ |
| | | មន្ត្រីរាជការ (កំនែទំរង់រដ្ឋបាល) | ១៥ | សេវាថែទាំសុខភាព | ២ |
| | | | | សុខមាលភាពសង្គម | ២ |
| | | | | ជីវសាស្ត្រ | ២ |
| ២០០៣ | ៤០ | កសិកម្ម (ការអភិវឌ្ឍន៍ជនបទ) | ១៥ | អប់រំ | ២ |
| | | | | សេដ្ឋកិច្ច | ២ |
| | | មន្ត្រីរាជការ (អានាម័យសាធារណ:) | ១៥ | សេវាថែទាំសុខាភាព | ២ |
| | | | | សុខមាលភាពសង្គម | ២ |
| | | | | ជីវសាស្ត្រ | ២ |
| ២០០៤ | ៥០ | កសិកម្ម (ការអភិវឌ្ឍន៍ជនបទ) | ២០ | អប់រំ | ៣ |
| | | | | សាធារណការ | ២ |
| | | រដ្ឋបាល (អង្គភាពស្វយ័តនៅតាមមូលដ្ឋាន) | ២០ | សេវាថែទាំសុខភាព | ៣ |
| | | | | កសិកម្ម | ២ |
| ២០០៥ | ៥០ | កសិកម្ម (ការអភិវឌ្ឍន៍ជនបទ) | ២០ | អប់រំ | ៣ |
| | | | | ជីវសាស្ត្រ | ២ |
| | | រដ្ឋបាល (វិមជ្ឈការ អង្គភាពស្វយ័តនៅតាមមូលដ្ឋាន) | ២០ | សេវាថែទាំសុខភាព | ៣ |
| | | | | កសិកម្ម | ២ |
| ២០០៦ | ៦០ | កសិកម្ម (អភិវឌ្ឍន៍ភូមិនៅតំបន់ជនបទ) | ២៤ | អប់រំ | ៣ |
| | | រដ្ឋបាល (វិមជ្ឈការ អង្គភាពស្វយ័តនៅតាមមូលដ្ឋាន) | ២៤ | សេវាថែទាំសុខភាព | ៣ |
| | | | | បរិស្ថាន | ៦ |
| Total | ៣២០ | | ២៤៨ | | ៧២ |

## ២.៦.គំរោងសហប្រតិបត្តិការបច្ចេកទេស

គំរោងសហប្រតិបត្តិការបច្ចេកទេស គឺជាផ្នែកមួយនៃការទ្រទ្រង់ផ្នែកបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៏តាមរយៈការប្រើប្រាស់រួមបញ្ចូលគ្នានូវសមាសធាតុ ដូចជាជំនាញការ វគ្គបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋាភិបាលនៅជប៉ុន និង ការផ្គត់ផ្គង់សំភារៈ និង ឧបករណ៏ ។ សមាសធាតុទាំងនេះត្រូវបានប្រើប្រាស់ក្នុងលក្ខណៈជាប្រព័ន្ធ ត្រូវបានគេរៀបចំ និង គ្រប់គ្រង តាមរបៀបសមាហរណកម្ម ផ្អែកលើដំណើរការទាំងមូលនៃគំរោងមួយ គិតចាប់ពីដំណាក់កាលនៃការបង្កើត ការអនុវត្តន៏ និង វាយតំលៃគំរោង ។ សព្វថ្ងៃ មានគំរោងប្រភេទនេះ ចំនួន ១៦ កំពុងត្រូវបានគេអនុវត្ត នៅកម្ពុជា ។

**(១) គំរោងស្តីពីការបញ្ជ្រាបយេនឌ័រ និង ការអភិវឌ្ឍន៏គោលនយោបាយតាមរយៈការពង្រឹងសមត្ថភាពផ្នែកព័ត៌មាន និង ស្រាវជ្រាវ**

គំរោងនេះ សំដៅលើការបង្កើតយន្តការដែលប្រកបដោយប្រសិទ្ធភាពមួយសំរាប់ការតំរង់ទិសយេនឌ័រ តាមរយៈការពង្រឹងសមត្ថភាពរបស់ក្រសួងកិច្ចការនារី ។ សកម្មភាពសំខាន់ៗរបស់គំរោងមានដូចជា ការកសាងសមត្ថភាពផ្នែកព័ត៌មាន និង ស្ថិតិយេនឌ័រដល់បុគ្គលិករបស់ក្រសួង សិក្ខាសាលា វិភាគពីព័ត៌មាន ស្ថិតិយេនឌ័រ និង គំរោង ស្រាវជ្រាវអំពីយេនឌ័រ សិក្ខាសាលាបង្កើតពង្រាងគោលនយោបាយដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ និង ការអនុវត្តន៏គំរោងសាកល្បង និង គោលនយោបាយដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រដែលបានបង្កើតរួចហើយ ។ ក្រសួងកិច្ចការនារី ជាសមភាគីនៃគំរោង ។

**រយៈពេលនៃគំរោង :** មេសា ២០០៣-មិនា ២០០៨
**ទីតាំងគំរោង :** ក្រសួងកិច្ចការនារី កំពង់ចាម

**(២) គំរោងកសាងធនធានមនុស្សវិស័យសហវេជ្ជសាស្ត្រ**

គំរោងនេះចាប់ផ្តើមនៅខែ កញ្ញាឆ្នាំ ២០០៣ សំដៅស្ថាបនាសមត្ថភាពធនធានមនុស្សសហវេជ្ជសាស្ត្រ សំរាប់ស្ថាប័នសុខភាពសាធារណៈ ។ គំរោង មានរួមបញ្ចូលសមាសធាតុពីរសំខាន់ៗ ។ ទីមួយ គឺការពង្រឹងយុទ្ធសាស្ត្រធនធានមនុស្សសហវេជ្ជសាស្ត្រ រួមមានទាំងការបង្កើតយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍន៏ធនធានមនុស្សនៃវិស័យនេះ ការបង្កើតអោយមានប្រព័ន្ធទទួលស្គាល់សមត្ថភាព និង ការកំនត់និយមន័យបច្ចេកវិទ្យានៃការត្រួតពិនិត្យសុខភាពដោយប្រើប្រាស់កម្មរស្មីអ៊ិក ជាដើម ។ ទីពីរ គឺការពង្រឹងសមត្ថភាពស្ថាប័នសំរាប់ការបណ្តុះបណ្តាជាមូលដ្ឋាននៃវិស័យសហវេជ្ជសាស្ត្រ រួមមានសកម្មភាព ដូចជា កែសំរួលឡើងវិញនូវ កំរងមុខវិជ្ជា សៀវភៅជំនាញ និង សមត្ថភាពគ្រប់គ្រងរបស់សាលា ។ នាយកដ្ឋានអភិវឌ្ឍន៏

**រយៈពេលនៃគំរោង :** កញ្ញា ២០០៣-កញ្ញា ២០០៨
**ទីតាំងគំរោង :** មណ្ឌលសេវាសុខភាព (ភ្នំពេញ) មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ ខេត្តបាត់ដំបង ស្ទឹងត្រែង កំពត និង កំពង់ចាម

ធនធានមនុស្សនៃសាលាបច្ចេកទេសពេទ្យ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ទាំង៤ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល គឺជាសមភាគីរបស់គំរោង ។

**(៣) គំរោងពង្រឹងសមត្ថភាពរបស់នាយកដ្ឋានពន្ធដារកម្ពុជា**

គំរោងនេះមានគោលបំណងសំខាន់ក្នុងការពង្រឹងរដ្ឋបាលពន្ធដារតាមរយៈការពង្រឹងសមត្ថភាពក្រុមសវនករពន្ធដារ ។ ក្រុមសវនករទាំងនោះ ត្រូវបានបំពាក់បំប៉នដោយវគ្គសិក្សាជាច្រើន ទាំងនៅកម្ពុជា និង នៅប្រទេសជប៉ុន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាសមភាគីនៃគំរោង ។

**រយៈពេលគំរោង :** មករា ២០០៤-មករា ២០០៧
**ទីតាំងគំរោង :** នាយកដ្ឋានពន្ធដារ/ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**ព័តមានសំខាន់ៗ :**
២២ មករា ២០០៤ ហត្ថលេខាលើកំនត់ហេតុព្រមព្រៀងគំរោង

**(៤) គំរោងអភិវឌ្ឍន៏ច្បាប់ និង តុលាការ ដំណាក់កាលទី ២**

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានបន្តជួយពង្រាងក្រមរដ្ឋប្បវេនីយ និង ក្រមនីតិវិធីសំរាប់ក្រម រដ្ឋប្បវេនីយ តាំងពីឆ្នាំ ១៩៩៩ (ដំណាក់កាលទី១) ។ ដំណាក់កាលទី២នៃគំរោងចាប់ផ្តើមនៅខែមេសា ឆ្នាំ ២០០៤ សំដៅពង្រឹងដំណើរការច្បាប់នៃក្រមទាំងពីរខាងលើ និង ភាពស៊ីសង្វាក់គ្នានៃក្រមខាងលើ ទៅនឹងច្បាប់ និង លក្ខខ័ណ្ឌតិក្កផ្សេងទៀត ។ ក្រមរដ្ឋប្បវេនីយត្រូវបានអនុម័តរួចហើយដោយគណកម្មការដែលទទួលបន្ទុកនៃរដ្ឋសភាជាតិ និង រង់ចាំការអនុវត្តដោយ សម័យប្រជុំពេញអង្គរបស់សភា ។ សមភាគីរបស់គំរោង គឺក្រសួងយុត្តិធម ។

**រយៈពេលនៃគំរោង :** មេសា ២០០៤-មេសា ២០០៨
**ទីតាំងគំរោង :** ក្រសួងយុត្តិធម
**ពិត័មានសំខាន់ៗ :**
មេសា ២០០៤ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សារបស់គំរោង (R/D)

**(៥) មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន**

គំរោងនេះមានគោលបំណងសំខាន់ពីរ ។ ទីមួយ គឺការជំរុញការអនុវត្តន៏សេដ្ឋកិច្ចទីផ្សារតាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស ។ ទីពីរ គឺការពង្រឹងជាបន្ថែមទៀតនូវការយល់ដឹង និង សហការគ្នាទៅវិញទៅមករវាងកម្ពុជា និង ជប៉ុន តាមរយៈការពង្រឹងទំនាក់ទំនងមនុស្ស ។ សំដៅសំរេចគោលបំណងនេះ មជ្ឈមណ្ឌលបានគាំទ្រសកម្មភាពសំខាន់ៗ ចំនួន ៣ ដូចតទៅនេះ (ក) ការផ្តល់វគ្គសិក្សាអំពីការអភិវឌ្ឍន៏ធនធានមនុស្ស (ខ) ការសិក្សាភាសាជប៉ុន និង (គ) ការផ្លាស់ប្តូរកម្មសិក្សា ។ អ្នកដែលទទួលប្រយោជន៏ពីគំរោងនេះ អាចរាប់បញ្ចូលទាំងប្រជាជននៅតាមភូមិស្រុក មិនមែនក៏រិតត្រឹមតែ មន្ត្រីរាជការស៊ីវិលនៅតាមបណ្តាក្រសួង/ស្ថាប័នតែប៉ុណ្ណោះទេ ។ កំនត់ហេតុនៃការពិភាក្សា (Record of Discussion—R/D) របស់គំរោងត្រូវបានចុះ

**រយៈពេលនៃគំរោង :** មេសា ២០០៤-មិនា ២០០៩
**ទីតាំងនៃគំរោង :** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
**ពិត័មានសំខាន់ៗ :**
មិនា ២០០៤ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សា

ហត្ថលេខានៅខែ មិនា ឆ្នាំ ២០០៤ ហើយនៅដើមឆ្នាំ ២០០៦ កិច្ចសហប្រតិបត្តិការបច្ចេកទេសពេញលេញមួយនឹងត្រូវចាប់ផ្តើម ។ សមភាគីរបស់គំរោង គឺសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ/ក្រសួងអប់រំ យុវជន និង កីឡា ។

## (៦) គំរោងគ្រប់គ្រងជំងឺរបេង ដំណាក់កាលទី ២

**រយៈពេលនៃគំរោង :**
ដំណាក់កាលទី១ : សីហា ១៩៩៩-សីហា ២០០៤
ដំណាក់កាលទី២ : សីហា ២០០៤-សីហា ២០០៩
**ទីតាំងគំរោង :** មជ្ឈមណ្ឌលជាតិគ្រប់គ្រងរោគរបេង និង ឃ្លង់ CENAT/L, ភ្នំពេញ

គោលបំណងសំខាន់របស់គំរោង គឺទ្រទ្រង់ដល់កម្មវិធីជាតិប្រឆាំងជំងឺរបេងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈផែនការជាតិគ្រប់គ្រងជំងឺរបេង (NTP) សំដៅសំរេចនូវអត្រាព្យាបាលសះស្បើយអោយបានច្រើនជាង ៨៥% និងអត្រារកឃើញអ្នកផ្ទុកមេរោគអោយបានយ៉ាងតិច ៧០% ។ គោលដៅនៃគោលបំណងនេះ គឺការពង្រីកសេវាកម្មគ្រប់គ្រងជំងឺរបេងប្រកបដោយគុណភាពមួយអោយបានពេញទូទាំងប្រទេស តាមរយៈការអនុវត្តន៍ការព្យាបាលដោយវិធីសាស្ត្រលេបថ្នាំដោយទៀងទាត់នៅមុខវេជ្ជបណ្ឌិត (DOTS) ដែលត្រូវបានគេអនុវត្តតាមរយៈការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលជាតិគ្រប់គ្រងជំងឺរបេង និង រោគឃ្លង់ ការពង្រឹងមុខងាររបស់កម្មវិធីជាតិគ្រប់គ្រងជំងឺរបេង (NTP) ការពង្រឹងបណ្តាញស្រាវជ្រាវនៃមន្ទីរពិសោធន៍រោគរបេង និងសកម្មភាពទ្រទ្រង់ និង ស្រាវជ្រាវផ្សេងទៀត ។ គំរោងមុន (ដំណាក់កាលទីមួយ) បានប្រគល់ជូនមជ្ឈមណ្ឌលជាតិនូវអាគារថ្មីមួយនៅខែមិនា ឆ្នាំ ២០០១ ។ ក្រោយពីគំរោងនោះបានបញ្ចប់ គំរោងបន្ត (ដំណាក់កាលទី២) បានចាប់ផ្តើមនៅខែ សីហា ឆ្នាំ ២០០៤ ។ សមភាគីរបស់គំរោង គឺមជ្ឈមណ្ឌលជាតិគ្រប់គ្រងជំងឺរបេង និងរោគឃ្លង់ ។

## (៧) គំរោងកសាងសមត្ថភាព និង ពង្រឹងស្ថាប័ននៃវិស័យអគ្គិសនី

**រយៈពេលនៃគំរោង :** កញ្ញា ២០០៤-កញ្ញា ២០០៧
**ទីតាំងគំរោង :** អាជ្ញាធរអគ្គិសនីជាតិ (EAC) អង្គភាពអគ្គិសនី (EDC)
**ព័ត៌មានសំខាន់ៗ :**
១៦ កញ្ញា ២០០៤ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សា

គំរោងនេះមានគោលបំណងសំដៅចូលរួមចំណែកក្នុងការធានាការផ្គត់ផ្គង់ដោយសុវត្ថិភាព និង ទៀងទាត់នូវ ថាមពលអគ្គិសនីនៅកម្ពុជា តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និង ក្នុងរបៀបត្រឹមត្រូវនៃប្រព័ន្ធចែកចាយ និងនិយាមបច្ចេកទេសវិស័យអគ្គិសនី ។ សកម្មភាពសំខាន់ៗរបស់គំរោង មានដូចជាការបញ្ជូនជំនាញការ ការផ្តល់សំភារៈ និង ឧបករណ៍ចាំបាច់សំរាប់គំរោង និង ការផ្តល់ការបំពាក់បំប៉នតាមរយៈការសិក្សាដល់បុគ្គលិកសមភាគីដែលពាក់ព័ន្ធ ។ អាជ្ញាធរអគ្គិសនីកម្ពុជា និង អង្គភាពអគ្គិសនីកម្ពុជា និងបុគ្គលិកពាក់ព័ន្ធរបស់ស្ថាប័នទាំងពីរ គឺជាអ្នកទទួលប្រយោជន៍ដ៏ចំបងពីគំរោងនេះ ។ បច្ចុប្បន្ន មានជំនាញការរយៈពេលខ្លីចំនួនពីរនាក់ កំពុងធ្វើការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា និង អង្គភាពអគ្គិសនីកម្ពុជា ។

## (៨) គំរោងពង្រឹងការបណ្តុះបណ្តាផ្នែករដ្ឋប្បវេនីយនៅរាជបណ្ឌិតសភាវិជ្ជាជីវចៅក្រម និង រាជអាជ្ញារ

ស្របគ្នាជាមួយនឹងការអភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនបានបន្តសហការជាមួយរាជបណ្ឌិតសភាវិជ្ជាជីវចៅក្រម និង រាជអាជ្ញារ ដើម្បីពង្រឹងសមត្ថភាពក្នុងការផ្តល់ការបណ្តុះបណ្តាប្រកបដោយគុណភាពអំពីបញ្ហារដ្ឋប្បវេនីយដែលមានលើកនៅក្នុងពង្រាងក្រមរដ្ឋប្បវេនីយ និង ក្រមនិតិវិធីក្រមរដ្ឋប្បវេនីយ។ គំរោងផ្តោតជាសំខាន់លើការលើកកំពស់ កំរងមេរៀន ឯកសារបង្រៀន និង សមត្ថភាពអ្នកបង្រៀនអំពីបញ្ហារដ្ឋប្បវេនីយ ។ កំនត់ហេតុពិភាក្សានៃគំរោង (Record of Discussion)[1] ត្រូវបានចុះ ហត្ថលេខានៅថ្ងៃទី១០ខែវិច្ឆិកា ២០០៥ ។

| |
|---|
| **រយៈពេលគំរោង :** មករា ២០០៥-មិនា ២០០៨<br>**ទីតាំងគំរោង :** សាលាភូមិន្ទចៅក្រម និង រាជអាជ្ញារ<br>១០ វិច្ឆិកា ២០០៥ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សារបស់គំរោង (R/D) |

## (៩) គំរោងពង្រឹង និង ពង្រីកវារីវប្បកម្មទឹកសាបនៅកម្ពុជា

| |
|---|
| **រយៈពេលនៃគំរោង :** មិនា ២០០៥-កុម្ភៈ ២០១០<br>**ទីតាំងគំរោង :** នាយកដ្ឋានជលផល ខេត្ត ព្រៃវែង តាកែវ កំពត កំពង់ស្ពឺ |

គោលបំណងសំខាន់របស់គំរោង គឺពង្រីកបច្ចេកទេសវារីវប្បកម្មទឹកសាបធុនតូចអោយបានទូលំទូលាយនៅតំបន់ដែលបានដៅទុក ដើម្បីចូលរួមចំណែកក្នុងការបង្កើនផលិតកម្មវារីវប្បកម្មនៅតាមតំបន់ទាំងនោះ ។ លទ្ធផលរំពឹងទុករបស់គំរោង មានដូចតទៅនេះ : (ក) បណ្តុះបណ្តាកសិករផលិតត្រីពូជ ចេញពីកសិករដែលចិញ្ចឹមត្រីក្នុងទ្រង់ទ្រាយតូចបច្ចុប្បន្ន តាមរយៈការពង្រឹងបច្ចេកទេសវារីវប្បកម្ម (ខ) កែលំអបច្ចេកទេសចិញ្ចឹមត្រីខ្នាតតូច និង ពង្រីកបច្ចេកទេសបន្ថែម (គ) លើកកំពស់សកម្មភាពទាក់ទិននឹងការចិញ្ចឹមត្រី ដើម្បីផ្តល់ប្រយោជន៍បន្ថែមដល់កសិករក្រីក្រដែលគ្មានដី និង (ឃ) បង្កើតបណ្តាញពង្រីកវារីវប្បកម្មនៅតាមតំបន់ជនបទ ។ សមភាគីសំខាន់របស់គំរោង គឺក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

[1] សំរាប់គំរោងកិច្ចសហប្រតិបត្តិការបច្ចេកទេស កំនត់ហេតុនៃការពិភាក្សា គឺជាឯកសារមួយដែលបញ្ជាក់ពីការព្រមព្រៀងរវាងរាជរដ្ឋាភិបាលទាំងពីរ និងជាចំនុចចាប់ផ្តើមនៃគំរោង ។ ជាទូទៅ ក្នុងកំនត់ហេតុនោះ មានការបញ្ជាក់ពិកិច្ចសហប្រតិបត្តិការ និង ការទទួលខុសត្រូវលើការអនុវត្តន៏គំរោងដោយភាគីនីមួយៗ ។ ឯកសារដែលតែងតែភ្ជាប់ជាមួយនឹងកំនត់ហេតុ នៅពេលចុះហត្ថលេខា គឺគ្រោង ខ្លឹមសារសំខាន់ៗនៃគំរោង និងការបរិយាយពីសកម្មភាពគំរោង។ មុននឹងឈានទៅដល់កំនត់ហេតុនេះ ភាគីកម្ពុជា និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន អាចមានការពិភាក្សា និង ព្រមព្រៀងលើចំនុចមួយចំនួនស្តីពីគំរោង ដែលឆ្លុះបញ្ចាំងតាមរយៈឯកសារប្រជុំសំខាន់ៗដែលទាក់ទងនឹងគំរោង ផងដែរ ។

## (១០) គំរោងពង្រឹងស្ថិតិផ្លូវការនៅកម្ពុជា

គំរោងផ្ដោតជាសំខាន់លើភាពទៀងទាត់អាចប្រើការបាននៃស្ថិតិសំរាប់បណ្ដាអ្នករៀបចំគោលនយោបាយ អ្នករដ្ឋបាល អ្នកស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និង អ្នកប្រើប្រាស់ដទៃទៀត តាមរយៈការពង្រឹងសមត្ថភាពស្ថិតិបុគ្គលិករបស់វិទ្យាស្ថានជាតិស្ថិតិ បុគ្គលិកស្ថិតិខេត្ត និង បុគ្គលិកស្ថិតិនៅតាមបណ្ដាក្រសួង/ស្ថាប័នជំនាញទាំងឡាយ ។ កំនត់ហេតុពិភាក្សារបស់គំរោងត្រូវបានធ្វើ និង ព្រមព្រៀងរួចរាល់នៅខែ កក្កដា ឆ្នាំ ២០០៥ ។ លទ្ធផលនៃគំរោង ត្រូវបានគេរំពឹងទុកថា នឹងគ្របដណ្ដប់ទូទាំងកម្ពុជាក្នុងរូបភាពដូចជា គោលនយោបាយអភិវឌ្ឍន៍ប្រទេស ដែលមានលក្ខណៈស្របទៅនឹងស្ថានការណ៍ជាក់ស្ដែងផ្អែកលើស្ថិតិដែលអាចទុកចិត្តបានជាដើម ។

**រយៈពេលគំរោង :** សីហា ២០០៥ – សីហា ២០០៧
**ទីតាំងគំរោង :** វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ
**ព័ត៌មានសំខាន់ៗ :**
កក្កដា ២០០៥ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សារបស់គំរោង (R/D)

## (១១) គំរោងគ្រប់គ្រងហរិភ័យវិស័យគយ

គោលបំណងរបស់គំរោងគឺពង្រឹងចំនេះ និង ការយល់ដឹងអំពីវិធីសាស្ត្រគ្រប់គ្រងហរិភ័យសំរាប់វិស័យគយ តាមរយៈការបណ្ដុះបណ្ដាលមន្ត្រីគយកម្ពុជានៅប្រទេសជប៉ុន និងកម្ពុជា និងធ្វើការវិភាគ កំនត់បញ្ហាដូចជារៀបចំសំណុំទិន្នន័យដែលពាក់ព័ន្ធដើម្បីដំនើរការការគ្រប់គ្រងហរិភ័យដល់មន្ត្រីគយប្រចាំការនៅកំពង់ផែក្រុងព្រះសីហនុ ។

**រយៈពេលគំរោង :** ធ្នូ ២០០៥ – វិច្ឆិកា ២០០៧
**ទីតាំងគំរោង : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
ទីចាត់ការគយ និង រដ្ឋករ
**ព័ត៌មានសំខាន់ៗ :**
០៧ វិច្ឆិកា ២០០៥ : ហត្ថលេខាលើកំនត់ហេតុពិភាក្សាគំរោង (R/D)

## (១២) គំរោងពង្រឹងការអប់រំផ្នែកវិទ្យាសាស្ត្រ និង គណិតសាស្ត្រសំរាប់មធ្យមសិក្សា

គំរោងមានគោលបំណងសំខាន់ក្នុងការពង្រឹងគុណភាពអប់រំផ្នែកវិទ្យាសាស្ត្រ និងគណិតសាស្ត្រ សំរាប់កំរិតមធ្យមសិក្សា តាមរយៈការជួយដល់ក្រសួងអប់រំយុវជន និងកីឡាក្នុងការរៀបចំសំរួលកម្មវិធីសិក្សា និង ការបង្កើតសៀវភៅពុម្ពសំរាប់សិស្ស និង ឯកសារបង្រៀនសំរាប់គ្រូ ប្រើប្រាស់តាមគោលនយោបាយថ្មីអំពីមុខវិជ្ជា ។ មុខវិជ្ជាសំខាន់ៗចំនួន ៤ ដែលស្ថិតនៅក្នុងគំរោង មាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា សំរាប់ពីថ្នាក់ទី ១០ ដល់ទី១២ ។ ក្រសួងអប់រំ យុវជន និង កីឡា គឺជាសមភាគីគំរោង ។

**រយៈពេលនៃគំរោង :** វិច្ឆិកា ២០០៥-តុលា ២០០៨
**ទីតាំង :** ក្រសួងអប់រំ យុវជន និង កីឡា (ភ្នំពេញ)
**ព្រឹត្តការណ៍:**
វិច្ឆិកា ២០០៥ : ចុះហត្ថលេខាលើកំណត់ហេតុព្រមព្រៀង

## (១៣) គំរោងកសាងសមត្ថភាពវិស័យព្រៃឈើ ដំណាក់កាលទី ២

បន្តពីគំរោងមុនដែលបានចាប់ផ្តើមតាំងពីខែធ្នូ ឆ្នាំ ២០០១ និង បញ្ចប់នៅខែធ្នូ ២០០៤ ក្នុងការកសាងសមត្ថភាពរបស់បុគ្គលិករដ្ឋបាលព្រៃឈើនៅតាមផ្នែកសំខាន់មួយចំនួននៃការធ្វើផែនការ ការអនុវត្តន៍ ការត្រួតពិនិត្យ និង ការវាយតំលៃ ច្បាប់ គោលនយោបាយ ផែនការ និង គំរោងដែលទាក់ទងនឹងវិស័យព្រៃឈើ គំរោងនៅដំណាក់កាលទី ២ ដែលផ្តោតលើសហគមន៍ព្រៃឈើត្រូវបានគេអនុវត្តនៅខែ ធ្នូ ឆ្នាំ២០០៥ ហើយរំពឹងថានឹងត្រូវបញ្ចប់នៅក្នុងខែធ្នូ ២០១០ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គឺជាសមភាគីនៃគំរោង ។

**រយៈពេលនៃគំរោង :**
ដំណាក់កាលទី១: ធ្នូ ២០០១-ធ្នូ២០០៤
គំរោងសាកល្បង : ធ្នូ ២០០៤-ធ្នូ ២០០៥
ដំណាក់កាលទី២ : កញ្ញា ២០០៥-សីហា ២០១០
ទីតាំងគំរោង : មជ្ឈមណ្ឌលបណ្តុះបណ្តាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ភ្នំពេញ)
**ព័តិមានសំខាន់ៗ :**
១៤ ធ្នូ ២០០៥ : ចុះហត្ថលេខាលើកំនត់ហេតុពិភាក្សា ( ដំណាក់កាលទី២)

## (១៤) គំរោងលើកកំពស់ប្រព័ន្ធគ្រប់គ្រងសំភារៈវេជ្ជសាស្ត្រ

គោលបំណងសំខាន់របស់គំរោងគឺការណែនាំអំពីសកម្មភាពថែរក្សាសំភារៈវេជ្ជសាស្ត្រដល់មន្ទីរពេទ្យជាតិមួយ ចំនួន សំភារៈនៃកញ្ចប់សកម្មភាពបន្ថែមសំរាប់មន្ទីរពេទ្យតំបន់ចំនួន ៣ ដែលជាមន្ទីរពេទ្យតំបន់សំខាន់ៗនៃ ស្ថាប័នសុខភាពសាធារណៈកម្ពុជា ។ ម៉្យាងទៀតគំរោងក៏នឹងជួយដល់ក្រសួងសុខាភិបាលក្នុងការពង្រឹងសេចក្តី ណែនាំរដ្ឋបាលសំរាប់នាយកដ្ឋានគ្រប់គ្រងសំភារៈវេជ្ជសាស្ត្រ ក៏ដូចជាការពង្រឹងជំនាញរបស់មន្ត្រីបច្ចេកទេស សំភារៈវេជ្ជសាស្ត្រប្រចាំការនៅមន្ទីរពេទ្យជាតិ និង មន្ទីរពេទ្យតំបន់ទាំង ៣ និង ការពង្រឹងសមត្ថភាពអ្នកគ្រប់គ្រង សំភារៈវេជ្ជសាស្ត្រប្រចាំមន្ទីរសុខាភិបាលនៅតាមខេត្ត ពេទ្យជាតិ និង កញ្ចប់សកម្មភាពបន្ថែមសំរាប់មន្ទីរពេទ្យតំបន់ទាំង ៣ ។

**រយៈពេលគំរោង :** មករា ២០០៦-ធ្នូ ២០០៨
**ទីតាំងគំរោង :** ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក ( ភ្នំពេញ)

## (១៥) គំរោងមជ្ឈមណ្ឌលសេវាកម្មបច្ចេកទេសសំរាប់ប្រព័ន្ធធារាសាស្ត្រដំណាក់កាលទី២

គោលបំណងរបស់គំរោង គឺជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្ថាបនាមជ្ឈមណ្ឌលសេវាកម្មបច្ចេកទេសជាតិមួយសំរាប់ប្រព័ន្ធធារាសាស្ត្រ ។ មជ្ឈមណ្ឌលជាតិនោះនឹងជួយដល់ការស្តារ និង ទ្រទ្រង់ដល់សំភារៈដែលបានខូចខាតពីមុនមក ជួយពង្រឹងសមត្ថភាពរបស់វិស្វករ និង អ្នកជំនាញជាតិ និង ជួយជំរុញដល់ការចងក្រង

**រយៈពេលនៃគំរោង :** មករា ២០០១-មករា ២០០៦ ( ដំណាក់កាលទី១)
មករា ២០០៦-កក្កដា ២០០៩ ( ដំណាក់កាលទី២)
**ទីតាំងគំរោង :** មជ្ឈមណ្ឌលសេវាកម្មបច្ចេកទេស (TSC) ខេត្តកណ្តាល តាកែវ ពោធិសាត ( ទិតាំងសាកល្បង)
ប្រពន្ធធារាសាស្ត្រស្រុកកណ្តាលស្ទឹង ( ទិតាំងគំរូ)
**ពិត័មានសំខាន់ៗ :**
ចុងខែកក្កដា ២០០៥ : បញ្ចប់ការវាយតំលៃសរុបរបស់គំរោង

សហគមន៍កសិករសំរាប់ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយ ប្រសិទ្ធភាព ។ ក្រសួងធនធានទឹក និង ឧត្តុនិយម គឺជាសមភាគីរបស់គំរោង ។ បច្ចុប្បន្ន ការវាយតំលៃបញ្ចប់លើគំរោង ត្រូវបានគេធ្វើរួចរាល់ហើយក្នុងលទ្ធផលជាវិជ្ជមាន ។ ដំណាក់កាលទី២នៃគំរោងចាប់ផ្តើមនៅក្នុងខែ មករា ២០០៦ ។

## (១៦) គំរោងពង្រឹងការគ្រប់គ្រងកាកសំណល់រឹងក្នុងទីក្រុងភ្នំពេញ

**រយៈពេលនៃគំរោង :** តុលា ២០០៦-តុលា ២០០៩
**ទីតាំងគំរោង :** រដ្ឋករកាកសំណល់រឹងភ្នំពេញ

**ពិត័មានសំខាន់ៗ :**
១៥ មិនា ២០០៦ : ចុះហត្ថលេខាលើកំនត់ហេតុព្រមព្រៀងគំរោង

ផ្អែកលើអនុសាសន៍នៃការសិក្សាអំពីការគ្រប់គ្រងកាកសំណល់រឹងនៅទីក្រុងភ្នំពេញដែលបានធ្វើ និង បញ្ចប់នៅ ខែមិនា ២០០៥ គំរោងសហប្រតិបត្តិការបច្ចេកទេសត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៥ ខែតុលា ២០០៦ ។ គោលបំណង ចំបងរបស់គមរោងគឺការពង្រឹងសមត្ថភាពរដ្ឋករកាកសំណល់រឹងភ្នំពេញ ដើម្បីអាចអោយអាជ្ញាធរមួយនេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រមូលកាកសំណល់ ផ្ទេរកាកសំណល់ចោលចុងក្រោយ និង ចាត់ចែងកាកសំណល់ទាំងនោះក្រោយការ ផ្ទេរ ។ រដ្ឋករកាកសំណល់រឹងភ្នំពេញ គឺជាដៃគូដ៏សំខាន់របស់គំរោង ។

## (១៧) គំរោងពង្រឹងសុត្ថិភាពចរាចរណ៍នៅទីក្រុងភ្នំពេញរបស់ព្រះរាជាណាចក្រកម្ពុជា

គោលបំណងចំបងបំផុតនៃគំរោងគឺការធ្វើអោយកាន់តែប្រសើរនូវស្ថានភាពចរាចរណ៍ទីក្រុង ជាមួយនឹងការកាត់បន្ថយគ្រោះថ្នាក់ និងភាពកកស្ទះផ្នែកចរាចរណ៍ដោយ (១) កែលំអផ្លូវខ្វែងសំខាន់ៗ (២) ផ្តល់ការអប់រំអំពីការបើកបរ (៣) ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ ។

| | | |
|---|---|---|
| **រយៈពេលគំរោង** | ២ ឆ្នាំ | |
| **ទីតាំងគំរោង** | ភ្នំពេញ | |
| **ព្រឹត្តិការណ៍សំខាន់** | ២៨ កក្កដា ២០០៦ | ចុះហត្ថលេខាលើកំនត់ហេតុអង្គប្រជុំ |
| | ១២ ធ្នូ ២០០៦ | ចុះហត្ថលេខាលើកិច្ចព្រមព្រៀង គំរោង |

ជំនាញការឯកទេសខាងសុវត្ថិភាពចរាចរណ៍ ការកែលំអ ផ្លូវខ្វែង ការអប់រំអំពីការបើកបរ និង ការពង្រឹងការ អនុវត្តន៍ច្បាប់ចរាចរណ៍ គ្រូវរៀបចំសិក្ខាសាលា និង សំភារៈគំរោងចាំបាច់មួយចំនួន នឹងត្រូវបញ្ជូនមក និង ផ្តល់អោយកម្ពុជា ។

នាយកដ្ឋានសាធារណការ និងដឹកជញ្ជូនដែល ស្ថិតនៅចំនុះអោយសាលាក្រុងភ្នំពេញ នាយកដ្ឋានការដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និង ដឹកជញ្ជូន និងប៉ូលីស ចរាចរណ៍

ក្រុងភ្នំពេញ គឺជាសមភាគីសំខាន់របស់គំរោង ។ សមត្ថភាព ក្នុងការកែលំអផ្លូវខ្មែររបស់នាយកដ្ឋានសាធារណៈ ការ និង ដឹកជញ្ជូន ការអប់រំអំពីការបើកបររបស់នាយកដ្ឋានដឹក ជញ្ជូនផ្លូវគោក និង សមត្ថភាពក្នុងការអនុវត្តន៏ច្បាប់ចរាចរណ៏ របស់ប៉ូលីសចរាចរណ៏ នឹងត្រូវបានគេពង្រឹងតាមរយៈ ដំណើរការនៃគំរោង ។

**(១៨) គំរោងស្តារនិងកែលំអជាបន្ទាន់នូវឧត្តុនិយមអាកាសចរស៊ីវិល**

គោលដៅសំខាន់របស់គំរោងគឺការកែលំអប្រព័ន្ធចរាចរណ៏ និង តំបន់ផ្តល់ព័តមានហោះហើរផ្លូវអាកាសដោយពង្រឹងបច្ចេកទេសព្យាករណ៏អាកាសធាតុ ។ ជំនាញការសំរាប់រយៈពេលវែងផ្នែកបច្ចេកទេសឧត្តុនិយមផ្លូវអាកាសមួយរូប ជំនាញការរយៈពេលខ្លីពីររូបសំរាប់ផ្នែកជុសជុលឧបករណ៏ឧត្តុនិយម និង ព្យាករណ៏អាកាសធាតុតាមរយៈ MTSAT និងឧបករណ៏ សំភារៈចាំបាច់មួយចំនួនត្រូវបានបញ្ជូន និង ផ្តល់ ដើម្បីការអនុវត្តន៏គំរោង ។

| | | |
|---|---|---|
| **រយៈពេលគំរោង** | ១៧ ខែគិតពីខែវិច្ឆិកា ២០០៦ | |
| **ទីតាំងគំរោង** | ទូទាំងប្រទេស | |
| **ព្រឹត្តិការណ៏ សំខាន់** | ១៩ កញ្ញា ២០០៦ | ចុះហត្ថលេខាលើកិច្ចប្រមព្រៀងនៃ គំរោង និង កំនត់ហេតុអង្គប្រជុំ |
| | ៤ ធ្នូ ២០០៦ | បញ្ជូនជំនាញការរយៈពេលវែង |

នាយកដ្ឋានឧត្តុនិយមនៃក្រសួងធនធានទឹក និង ឧត្តុនិយម និង នាយកដ្ឋានប្រតិបត្តិការហោះហើរ និងសុវត្ថិភាពផ្លូវអាកាសនៃអគ្គនាយកដ្ឋានអាកាសចរណ៏ស៊ីវិល គឺជាសមភាគីដ៏ចំបងរបស់គំរោង ។ នៅពេលអនុវត្តគំរោង សមត្ថភាពរបស់នាយកដ្ឋានទាំងពីរដែលពាក់ព័ន្ធនឹងត្រូវបានពង្រឹង ។

## ២.៧. កិច្ចសហប្រតិបត្តិការតាមរយៈការផ្តល់ឧបករណ៍ និង សំភារៈសំរាប់ទ្រទ្រង់ដល់ការអភិវឌ្ឍន៍[2]

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានបន្តជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍នូវសំភារៈពេទ្យងាយៗ ថ្នាំសំរាប់ព្យាបាលជំងឺ និង សំភារៈ និង ឧបករណ៍សំខាន់ៗដទៃទៀតដែលផ្តល់តែឯកឯង តាមរយៈ រឺក្នុងលក្ខណៈសហការជាមួយអ្នកផ្តល់ជំនួយផ្សេងទៀតដូចជា អង្គការសុខភាពពិភពលោក (WHO) និង មូលនិធិអង្គការសហប្រជាជាតិដើម្បីការអប់រំកុមារ (UNICEF) ។ នៅប្រទេសកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានជួយផ្គត់ផ្គង់សំភារៈតាមបែបផែនរបៀបនេះ លើគំរោងចំនួនបីសំខាន់ៗ នៅក្នុងឆ្នាំសារពើពន្ធ ២០០៤ (គិតពី ដើមខែមេសា ២០០៤ ដល់ចុងខែមិនា ២០០៥) ។

### (១) សំភារៈសំរាប់ទ្រទ្រង់ដល់កម្មវិធីសុខភាពមាតា និង ទារក

ក្នុងកិច្ចប្រឹងប្រែងពង្រឹងស្តង់ដាសេវាថែទាំសុខភាពមាតា និងទារក នៅកម្ពុជា តាមរយៈការសហការពហុនិងទ្វេភាគីជាមួយ UNICEF ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានផ្តល់ថ្នាំដូចជាអង់ទិប៊ីយ៉ូទិក និង វីតាមីនអេ ក្នុងទឹកប្រាក់ចំនួន ១៥៦ 000 ដុល្លាសហរដ្ឋអាមេរិក ។ សកម្មភាពនេះ បានបន្តធ្វើចាប់តាំងពីឆ្នាំ ១៩៩៨ រហូតមកទល់នឹងបច្ចុប្បន្ន ។ សកម្មភាពគំរោងគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ។ ក្រសួងសុខាភិបាល គឺជាសមភាគីរបស់គំរោង ។

### (២) កម្មវិធីគ្រប់គ្រងជំងឺរឆ្លង

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានផ្តល់ជាវ៉ាក់សាំងសំរាប់ការពារជំងឺជាច្រើនដូចជា BCG កញ្ជ្រិល ជំងឺថ្លើមប្រភេទ B ជំងឺតេតានុស គិតជាទឹកប្រាក់សរុប ៣៦២ ៤៤៨ ដុល្លាអាមេរិក ដល់កម្មវិធីពង្រីកការបង្ការជំងឺឆ្លង ដើម្បីកាត់បន្ថយអត្រាស្លាប់របស់ទារកនៅកម្ពុជា តាមរយៈការសហការទ្វេភាគី/ពហុភាគី ជាមួយនឹងមូលនិធិអង្គការសហប្រជាជាតិដើម្បីការអប់រំកុមារ/អង្គការសុខភាពពិភពលោក ។ សកម្មភាពនៃគំរោងបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩២ រហូតមកទល់នឹងបច្ចុប្បន្ន ។ គំរោងនឹងគ្របដណ្តប់លើកម្ពុជាទាំងមូល ។ កម្មវិធីជាតិបង្ការជំងឺឆ្លង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល គឺជាសមភាគីនៃគំរោង ។

[2] កិច្ចសហប្រតិបត្តិការរបៀបនេះ ធ្វើឡើងសំរាប់តែផ្នែកដែលទាក់ទងនឹងវិស័យសុខាភិបាល ហើយទៅនឹងគោលដៅមួយចំនួនប៉ុណ្ណោះ ដូចជា : ជំងឺឆ្លង សុខភាពមាតា និងទារក ផនការគ្រួសារ និង ការទ្រទ្រង់ដល់ការគ្រប់គ្រងកំនើនប្រជាជន និង មេរោគហ៊ីវ ។

## ២.៨.ការសិក្សាអភិវឌ្ឍន៍

ការសិក្សាអភិវឌ្ឍន៍ គឺជាការសិក្សាដែលគេអនុវត្តដើម្បីទ្រទ្រង់ដល់ការបង្កើតផែនការអភិវឌ្ឍន៍សំរាប់គំរោងការអភិវឌ្ឍន៍វិស័យសាធារណៈ ដែលនឹងចូលរួមចំណែកដល់ការអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ នៅប្រទេសកម្ពុជា បច្ចុប្បន្នមានការសិក្សាប្រភេទនេះ ចំនួន ៩ [៣] ដែលធ្វើឡើងដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មានដូចខាងក្រោម :

### (១) ការសិក្សាពីលទ្ធភាពនៃការស្ថាបនាទីផ្សារសេរីសំរាប់ការដោះដូរស្រូវនៅកម្ពុជា

**តំបន់សិក្សា :** ព្រៃវែង បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម កំពង់ធំ ពោធិសាត់ កណ្តាល កំពង់ឆ្នាំង ស្វាយរៀង កំពត កំពង់ស្ពឺ តាកែវ

**ព័ត៌មានទាក់ទងនឹងគំរោង :**
២៤ មិនា ២០០៣ : ចុះហត្ថលេខាលើ S/W (Scope of Work)
មករា ២០០៤ : ការសិក្សាពេញលេញចាប់ផ្តើម
ឧសភា ២០០៤: របាយការណ៍បណ្តោះអាសន្ន (១)
មិនា ២០០៦ : បញ្ចប់ការស្រាវជ្រាវសំខាន់នៃគំរោង

ក្រុមហ៊ុនទីប្រឹក្សា : Overseas Merchandise Inspection Co.,Ltd. And Sanyu Consultants Inc. (JV)

ការសិក្សានឹងសំរេចគោលដៅលទ្ធផល ដូចតទៅនេះ ។ ទីមួយ ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធទីផ្សារស្រូវ (សំរាប់ការកំនត់តំលៃសមស្របនៃស្រូវ) ជាមួយនឹងការកាត់បន្ថយភាពខុសគ្នានៃតំលៃស្រូវដែលប្រែប្រួលទៅតាមតំបន់ និង រដូវ និង ការបង្កើតសមតាថ្លៃ រវាងថ្លៃផលិត/លក់ដុំ និង ថ្លៃលក់រាយ ។ ទីពីរ ផ្តល់ព័ត៌មានអំពីថ្លៃអង្ករ និង ព័ត៌មានដទៃទៀតដែលទាក់ទងនឹងអង្ករពីខេត្តនីមួយៗ (ដើម្បីធានាចេរភាពនៃការផ្គត់ផ្គង់ ) ។ ទីបី បង្កើតស្តង់ដាគុណភាពសំរាប់អង្ករ (សំដៅពង្រឹងគុណភាព អង្ករ) ជាមួយនឹងការជំរុញអោយមានការយកចិត្តទុកដាក់លើស្តង់ដាគុណភាពនៅគ្រប់ដំណាក់កាលនៃប្រតិបត្តិការ និង ការពង្រឹងបច្ចេកទេសផលិតកម្មស្រូវក្រោយពេលច្រូតកាត់ និង ការកំនត់ថ្លៃសមតាទៅតាមភាពផ្សេងៗគ្នានៃគុណភាព អង្ករ/ស្រូវ ។ ទីបួន បង្កបរិយាកាសសំរាប់ការដោះដូរក្នុងតំបន់ សំដៅកាត់បន្ថយពាណិជ្ជកម្មខុសច្បាប់នៅតាមព្រំដែន និង ការបង្កើនការកត់ត្រាអំពីប្រតិបត្តិការស្រូវដែលសកម្មភាពនេះអាចនាំទៅដល់ការកាត់បន្ថយកន្លែងត្រួតពិនិត្យស្រូវ ខុសច្បាប់ និង សំរួលដល់ការត្រួតពិនិត្យប្រព័ន្ធអនុវត្តការដោះដូរ ឧទាហរណ៍ដូចជា ច្បាប់អាជីវកម្មស្រូវ និង ច្បាប់ទាក់ទងនឹងការបង់ពន្ធស្រូវ ។ លទ្ធផលនៃគំរោង នឹងគ្របដណ្តប់ខេត្ត ចំនួន ១៣ របស់កម្ពុជា ។ ក្រសួងពាណិជ្ជកម្ម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គឺជាសមភាគីរបស់គំរោង ។

[3] ទោះបីជាការសិក្សានៅមិនទាន់ត្រូវបានគេចាប់ផ្តើមនៅឡើយនៅពេលធ្វើរបាយការណ៍សំរាប់ខែកពានេះ កិច្ចប្រមព្រៀងកំនត់ពីទំហំនៃការសិក្សា ត្រូវបានគេចុះហត្ថលេខារួចហើយកាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ។

**(២) ការសិក្សាអំពីការអភិវឌ្ឍន៍ស៊ីជំរៅនៃវិស័យកសិកម្មនៃអាងព្រែកត្នោត**

គោលបំណងសំខាន់របស់គំរោង គឺ (១) ការបង្កើតផែនការមេសំរាប់ការអភិវឌ្ឍន៍កសិកម្មដើម្បីពង្រឹងផលិតភាពកសិកម្មនៅអាងព្រែកត្នោត (២) ការសិក្សាលទ្ធភាពលើការស្តារឧបករណ៍ស្រោចស្រព និង ប្រលាយដែលត្រូវការចាំបាច់ និង បន្ទាន់សំរាប់ការពង្រឹងការដាំដុះស្រូវ (៣) ការរៀបចំផែនការព្យាករណ៍ និង ផ្តល់ព័តិមានអំពីទឹកជំនន់ និង (៤) ការផ្ទេរបច្ចេកទេសការងារដល់មន្ត្រីសមភាគីក្នុងលក្ខណៈជាការបណ្តុះបណ្តាលតាមរយៈការងារក្នុងកំឡុងពេលសិក្សា ។ សកម្មភាពសំខាន់ៗរបស់គំរោងត្រូវបានបែងចែកជាពីរដំណាក់កាល ។ នៅដំណាក់កាលទីមួយការសិក្សាដូចតទៅនេះត្រូវបានរៀបចំ : ការសិក្សាជាមូលដ្ឋាន ពង្រាងផែនការមេ ផែនការតាមដានផ្នែកធារាសាស្ត្រ និង ក្របខណ្ឌ័សំរាប់ផែនការព្យាករណ៍ និង អោយព័តិមានអំពីទឹកជំនន់ ។ នៅដំណាក់កាលទីពីរមាន សកម្មភាពមួយចំនួនដូចតទៅនេះ : ផែនការមេដែលផ្អែកលើការអនុវត្តន៏កត្តាជាអាទិភាព (ដូចជាគំរោងសាកល្បង) ការសិក្សាលទ្ធភាពលើគំរោងដែលមានអាទិភាពខ្ពស់ (ក្នុងរយៈពេលមួយឆ្នាំ) ការតាមដានផែនការអង្កេតផ្នែក ធារាសាស្ត្រ ការរៀបចំផែនការព្យាករណ៍ និង ផ្តល់ព័តិមានអំពីទឹកជំនន់ និង ការបញ្ចប់ផែនការមេ ។ សមភាគីរបស់ គំរោង គឺក្រសួងធនធានទឹក និង ឧត្តុនិយម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ ការផ្ទេរបច្ចេកទេសការងារ ត្រូវបានកំនត់ជាសកម្មភាពដែលត្រូវបន្តធ្វើនៅគ្រប់ដំណាក់កាលនៃគំរោង ។

| |
|---|
| **តំបន់សិក្សា** : កំពង់ស្ពឺ និង កណ្តាល |
| **ព័តិមានទាក់ទង :**<br>មេសា ២០០៥ : ចុះហត្ថលេខាលើកំនត់ទំហំនៃការសិក្សា<br>កក្កដា ២០០៥ : របាយការណ៏បឋម<br>ការសិក្សាពេញលេញចាប់ផ្តើម |
| ទីប្រឹក្សា : Nippon Koei Co., Ltd. |

**(៣) ការសិក្សាពីការគាំទ្រផ្នែកគោលនយោបាយសេដ្ឋកិច្ចនៅកម្ពុជា**

គំរោងនេះជាសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា និង បានអនុម័តពីរដ្ឋាភិបាលជប៉ុនសំរាប់ជំនួយដល់កម្ពុជា ដែលមានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ជាអ្នកសហការអនុវត្តគំរោង ។ គោលបំណងសំខាន់ៗរបស់គំរោងគឺជំរុញជាបន្ថែមអោយមានការវិនិយោគដោយផ្ទាល់ពីបរទេសនៅកម្ពុជា ជាពិសេសការវិនិយោគផ្ទាល់ពីប្រទេសជប៉ុន។ ការសិក្សានេះនឹងគ្របដណ្តប់លើប្រទេសកម្ពុជាទាំងមូល ហើយ ផ្តោតលើសកម្មភាពសំខាន់ៗចំនួន ៥ ដូចជា (១)វាយតំលៃពីបរិយាកាសវិនិយោគផ្ទាល់ពីបរទេស (FDI) នៅកម្ពុជា (២) ស្វែងយល់ពីតំរូវការរបស់ក្រុមហ៊ុនវិនិយោគបរទេស សំខាន់ៗរបស់ជប៉ុន និង ប្រទេសអាស៊ាន (៣) វាយតំលៃពីឧស្សាហកម្មសំខាន់ៗដែលជាសក្តានុពលរបស់កម្ពុជា ដើម្បីទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេសពីប្រទេសជប៉ុន និង ប្រទេសអាស៊ាន (៤) បង្កើតយុទ្ធសាស្ត្រ និង ផែនការ

| |
|---|
| **តំបន់សិក្សា** : ទូទាំងប្រទេស |
| **ព័តិមានទាក់ទង :**<br>២២ សីហា ២០០៥ : ចុះហត្ថលេខាលើកិច្ចប្រមព្រៀងនៃការសិក្សា<br>ធ្នូ ២០០៥ : គ្រោងនឹងចាប់ផ្តើមការសិក្សា |
| ក្រុមហ៊ុនទីប្រឹក្សា : **KRI International Corp. (JV), Nomura Research Institute** |

សកម្មភាពសំរាប់ជំរុញឧស្សាហកម្មតាមរយៈវិនិយោគទុនផ្ទាល់ពីបរទេស និង (៥) ពង្រឹង សមត្ថភាពរបស់ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB/CDC) ។ គំរោងនឹងចាប់ផ្តើម នៅខែ វិច្ឆិកា ឆ្នាំ ២០០៥ ហើយគ្រោងនឹងបញ្ចប់នៅ ខែ មិនា ឆ្នាំ ២០០៧ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាសមភាគីរបស់គំរោង ។

## (៤) ការសិក្សាអំពីផែនការមេនៃវិស័យនាវាចរណ៍ និង កំពង់ផែផ្លូវសមុទ្រសំរាប់កម្ពុជា

ឆ្លើយតបទៅនឹងសំណូមពរជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន នឹងសហការជាមួយអាជ្ញាធរ និង ស្ថាប័នរបស់កម្ពុជាដើម្បីធ្វើការសិក្សានេះ ។ ការសិក្សានឹងត្រូវបានគេធ្វើឡើង គ្របដណ្តប់លើវិស័យនាវាចរណ៍ និងកំពង់ផែសមុទ្ររបស់កម្ពុជា ក្នុងគោលបំណង : (១) បង្កើតអោយមានប្លង់មេសំរាប់ពង្រឹងលទ្ធភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យនាវាចរណ៍ នឹងកំពង់ផែសមុទ្រ (គោលបំណងនេះរំពឹងនឹងសំរេចបាននៅឆ្នាំ ២០២០) និង (២) ដាក់ចេញនូវផែនការ សកម្មភាពរយៈពេលខ្លីសំរាប់គាំទ្រដល់ការអនុវត្តន៏សកម្មភាពដែលចង្អុលបង្ហាញនៅក្នុងផែនការមេ (ឆ្នាំគោលដៅ ២០១០) ។

| តំបន់គ្របដណ្តប់ : |
| --- |
| **ព័តិមានសំខាន់ៗ :**<br>០៥ ធ្នូ ២០០៥ : ចុះហត្ថលេខាលើការកំនត់ទំហំនៃការសិក្សា S/W<br>វិច្ឆិកា ២០០៦ : របាយការណ៍លើកដំបូង<br>វិច្ឆិកា ២០០៦ : កិច្ចប្រជុំគណកម្មការគំរោងលើកទី ១ |

សកម្មភាពរបស់គំរោងមានដូចជា : (ក) ធ្វើការសិក្សា និង វិភាគពីស្ថានភាពបច្ចុប្បន្ន និងស្វែងយល់ពីបញ្ហាចំបងៗដែលមាន និង ត្រូវដោះស្រាយនៅក្នុងវិស័យនាវាចរណ៍ និង កំពង់ផែសមុទ្រកម្ពុជា (ខ) បង្កើតផែនការមេ (គ) ដាក់ចេញនូវផែនការសកម្មភាពរយៈពេលខ្លីសំរាប់ផែនការមេ និង (ឃ) ធ្វើការវាយតំលៃជាទូទៅ និង ផ្តល់ជាអនុសាសន៏សំរាប់ វិស័យនាវាចរណ៍ និង កំពង់ផែសមុទ្រកម្ពុជា ។ ក្រសួងសាធារណការ និងដឹកជញ្ជូនគឺជាសមភាគី នៃគំរោង ។

## (៥) គំរោងសិក្សាពីការពង្រឹងការផ្តល់សេវាសុខភាពសំរាប់មាតា និង ទារកនៅព្រះរាជាណាចក្រកម្ពុជា

| តំបន់គ្របដណ្តប់ : ទូទាំងប្រទេស |
| --- |
| ព័តិមានសំខាន់ៗរបស់គំរោង :<br>២៧ កុម្ភៈ ២០០៦ : កិច្ចព្រមព្រៀងនៃការសិក្សា (S/W) |

ឆ្លើយតបទៅនឹងសំណូមពរជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបន្តការគាំទ្រដល់ផ្នែកសុខភាពមាតា និង ទារកនៅកម្ពុជា បន្ទាប់ពីគំរោងគាំពារសុខភាពមាតានិងទារកត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ជាជំនួយដើម្បីធ្វើការសិក្សានេះសំរាប់កម្ពុជា ។

គោលបំណងសំខាន់នៃការសិក្សាគឺបញ្ជាក់អោយច្បាស់ពីស្ថានភាពបច្ចុប្បន្ននៃសុខភាពមាតានិងទារកនៅកម្ពុជាលើបញ្ហាសំខាន់ៗមួយចំនួនដូចជា ស្ថានភាពសុខភាព និង សេវាផ្តល់កំណើត ការបង្កើតផែនការសំរាប់កែលំអសេវាសំរាប់មាតានិងទារក ជាពិសេសសេវាដែលធានាដល់សុខភាពមាតាក្រោយពេលសំរាល ដែលកំរិត និង គុណភាពសេវាមាន

ការខុសគ្នាយ៉ាងខ្លាំងរវាងទីក្រុង និង ជនបទ នៃកម្ពុជា ។ ជាងនេះទៅទៀត គំរោងក៏នឹងពង្រឹងសមត្ថភាពវាយតំលៃ និង រៀបចំផែនការសេវាដែលទាក់ទងនឹងសុខភាពមាតា និង ទារកដល់បុគ្គលិកក្រសួងសុខាភិបាលដែលចូលរួមក្នុងការអនុវត្តន៍គំរោងផងដែរ ។

សកម្មភាពសំខាន់ៗនៃគំរោងរួមមាន : លើកកំពស់សមត្ថភាពរបស់ក្រសួងសុខាភិបាលក្នុងការវាយតំលៃ និង រៀបចំផែនការ ធ្វើការវិភាគអំពីស្ថានភាពនៃវិស័យសុខាភិបាលនៅកម្ពុជា ធ្វើការអង្កេតដោយផ្ទាល់ពីស្ថានភាពជាក់ស្តែងនៃសុខភាពមាតានិងទារកនៅខេត្តជាក់លាក់មួយ ធ្វើការវាយតំលៃនិងវិភាគអំពីការរីកចំរើននៃការអនុវត្តន៍សេវាសុខភាពមាតា និង ទារកនៅតាមតំបន់ជនបទ ពិនិត្យអំពីស្ថានភាពអភិវឌ្ឍន៍ធនធានមនុស្សក្នុងផ្នែកសុខភាពមាតា និង ទារក កំនត់បញ្ហា និង ដំណោះស្រាយសំរាប់បញ្ហាទាំងនោះ រៀបចំផែនការ និង យុទ្ធសាស្ត្រសំរាប់កែលំអសេវាសុខភាពមាតា និង ទារក តាមរយៈការបញ្ចូលផែនការ និង យុទ្ធសាស្ត្រទាំងនោះទៅក្នុងផែនការ និង យុទ្ធសាស្ត្រសុខាភិបាលជាតិ និង កំនត់ពីការគាំទ្រចាំបាច់ដទៃទៀតពីដៃគូអភិវឌ្ឍន៍ផ្សេងៗដែលមាន ។

## (៦) ផែនការមេសំរាប់ប្រព័ន្ធធារាសាស្ត្រ និង ប្រលាយសំខាន់ៗនៅព្រះរាជាណាចក្រកម្ពុជា

គោលបំណងសំខាន់របស់គមរោងគឺ : (ក) បង្កើតផែនការមេសំរាប់ប្រព័ន្ធធារាសាស្ត្រ និង ប្រលាយ ដើម្បីបង្កើនការគ្រប់គ្រងទឹក និង ផលិតភាពកសិកម្មនៅអាងទន្លេទាំងបួនដែលកំនត់ដោយគំរោង និង កំនត់ពីផែនការលំអិតសំរាប់តំបន់អតិភាពនៃទន្លេនីមួយៗ (ខ) ផ្ទេរបច្ចេកទេសដល់មន្ត្រីសមភាគីតាមរយៈផ្តល់ការបណ្តុះបណ្តាលើការងារជាក់ស្តែងក្នុងរយៈពេលអនុវត្តន៍គំរោង ។ សកម្មភាពសំខាន់ៗរបស់គំរោងត្រូវបានបែងចែកជាពីដំណាក់កាល ។ ដំណាក់កាលទីមួយ បង្កើតពង្រាងផែនការមេ រួមមានការអនុវត្តន៍ការសិក្សា ការអនុវត្តន៍ការអង្កេតឧត្តុនិយមវារីអគ្គិសនី បង្កើតពង្រាងផែនការមេទូទាំងតំបន់ទន្លេ និង ជ្រើសរើសតំបន់អតិភាពនៅតាមអាងនីមួយៗ ។

| |
|---|
| តំបន់គ្របដណ្តប់ : អាងទន្លេបាត់ដំបង អាងទន្លេមោងឬស្សី អាងទន្លេពោសាត និង អាងទន្លេបរិបូរណ៍ |
| ព័តិមានសំខាន់ៗរបស់គំរោង :<br>២៦ តុលា ២០០៦ : កិច្ចព្រមព្រៀង នៃការសិក្សា (S/W) |

ដំណាក់កាលទី២ បង្កើតផែនការលំអិតនៅតាមតំបន់អាទិភាពនិមួយៗ និងធ្វើការបញ្ចប់គមរោងមេ ។ សមភាគីសំខាន់របស់គំរោងគឺក្រសួងធនធានទឹក និង ឧត្តុនិយម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ២.៩.ជំនួយឥតសំណង

ជំនួយឥតសំណង គឺជាការផ្តល់ធនធានដល់រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ដោយពុំចាំបាច់អោយមានការសងត្រលប់មកវិញនៅពេលក្រោយឡើយ ។ ជំនួយរបៀបនេះ ធ្វើឡើងតាមរយៈធនធានដែលប្រើប្រាស់សំរាប់ការធ្វើលទ្ធកម្មឧបករណ៍ និង សំភារៈផ្សេងៗដោយរដ្ឋាភិបាលប្រទេសទទួលជំនួយ ដើម្បីជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសនោះ ។ ទាក់ទងទៅនឹងគំរោងប្រភេទនេះ ការងារដែលបំពេញដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនមានដូចជា ការសិក្សាមុនពេលបង្កើតគំរោង ដែលទាក់ទងជាសំខាន់ទៅនឹងការស្វែងរកអោយឃើញពីតំរូវការពិត និង រូបរាងប៉ាន់ស្មាននៃគំរោង ទាំងទំហំ ទាំងតំលៃ ការអនុវត្តន៏គំរោងដែលបង្កើតហើយក្នុងដំណាក់កាលមុនការព្រមព្រៀងលើកំនត់ទូតរួមគ្នា(Exchange of Note)[៤] រវាងរដ្ឋាភិបាលទាំងពីរ និង ការអនុវត្តន៏សកម្មភាពតាមដាន សំដៅធានា និង ពង្រឹងឥទ្ធិពលនៃគំរោង។ ស្ថានទូតជប៉ុនប្រចាំកម្ពុជា នឹងដើរតួនាទីចាប់ពីដំណាក់កាលសិក្សាវិស្វកម្មលំអិតរបស់គំរោង ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅខាងក្រោមនេះ របាយការណ៏រាប់បញ្ចូលទាំងអស់នូវគំរោងដែលកំពុងតែដំណើរការ ទោះជាគំរោងនោះបានស្ថិតនៅដំណាក់ការសិក្សាវិស្វកម្មលំអិតក៏ដោយ ។ របាយ-ការណ៏ប្រចាំខែនេះនឹងរាយការណ៏គ្រប់គំរោង ទាំងនោះរហូត ដល់គំរោងទាំងនោះ ត្រូវបានគេបញ្ចប់រួចរាល់ និងប្រគល់ដល់រាជរដ្ឋាភិបាលកម្ពុជា ។

<u>(១) ជំនួយឥតសំណងរបស់ជប៉ុនសំរាប់ការបណ្តុះបណ្តាលធនធានមនុស្ស</u>

គោលបំណងនៃកម្មវិធីអាហារូបករណ៏នេះ គឺផ្តល់ដល់ជនជាតិកម្ពុជានូវឱកាសសំរាប់ការស្រាវជ្រាវសិក្សា នៅឯមហាវិទ្យាល័យនានារបស់ជប៉ុន ទ្រទ្រង់ដល់រដ្ឋាភិបាលកម្ពុជាក្នុងការសំរបសំរួលផែនការអភិវឌ្ឍន៏ធនធានមនុស្ស និងពង្រីក និង ពង្រឹងទំនាក់ទំនងកម្ពុជា-ជប៉ុន ។ កម្មវិធីនេះ ផ្តោតជាសំខាន់លើ មន្ត្រីរដ្ឋាភិបាលវ័យក្មេងៗ ក៏ដូចជា

[4] កំនត់ទូតគឺជាចំនុចផ្តើមនៃគំរោងជំនួយឥតសំណង ។ ការផ្លាស់ប្តូរកំនត់ទូតរបស់គំរោងជំនួយឥតសំណងមួយ នឹងបន្តដោយការអនុវត្តន៏ការងារគំរោងនោះ ។ ជាទូទៅឯកសារនេះមានបញ្ជាក់ពីទំហំជំនួយឥតសំណងដែលរដ្ឋាភិបាលជប៉ុនផ្តល់ដល់រដ្ឋាភិបាលកម្ពុជា តាមគំរោងជាក់លាក់នីមួយៗ ។ តំណាងក្រសួងការបរទេសទាំងពីរគឺជាភាគីតំណាងសំរាប់ប្រទេសនីមួយៗក្នុងការចុះហត្ថលេខា ។

បុគ្គលិកបង្រៀននៃវិទ្យាស្ថានជាន់ខ្ពស់ អ្នកស្រាវជ្រាវ នានា ដើម្បីអោយពួកគេទទួលបានការសិក្សាក៏រិតបរិញ្ញាទោនៅក្នុងផ្នែកជាច្រើនដូចជា ច្បាប់ សេដ្ឋកិច្ច រដ្ឋបាលជំនួញ ទំនាក់ទំនងអន្តរជាតិ និង ដទៃទៀត ។ នៅក្នុងឆ្នាំសារពើពន្ធ ២០០០ និង ២០០១ មាននិស្សិតចំនួន ២០ នាក់ត្រូវបានបញ្ជូនទៅជប៉ុនក្នុងឆ្នាំនីមួយៗ ។ ចាប់ពីឆ្នាំសារពើពន្ធ ២០០៦ ចំនួននិស្សិត ដែលនឹងត្រូវបញ្ជូនទៅ នឹងកើនឡើងដល់ ២៥ នាក់ក្នុងមួយឆ្នាំ ។

| |
|---|
| **រយះពេលគំរោង :** វិច្ឆិកា ២០០១-<br>**ទីតាំងគំរោង : N/A** |
| សីហា ២០០០ : បញ្ជូនក្រុមបេសកកម្មសំរាប់ការសិក្សាដំបូងពីគំរោង<br>តុលា ២០០០ : បញ្ជូនក្រុមបេសកកម្មពន្យល់ និង ប្រឹក្សាយោបល់<br>១៦ វិច្ឆិកា ២០០០ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០០<br>កក្កដា-សីហា ២០០១ : បញ្ជូននិស្សិតទៅជប៉ុនលើកទី១ ( ឆ្នាំសារពើពន្ធ ២០០០)<br>២១ សីហា ២០០១ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០១<br>ថវិការគំរោងសរុបសំរាប់ឆ្នាំសារពើពន្ធ ២០០០ និង ២០០១ : ៤៧០ លានយេន<br>មិថុនា ២០០២ : បញ្ជូននិស្សិតទៅជប៉ុនលើកទី ២ ( ឆ្នាំសារពើពន្ធ ២០០១)<br>២៧ សីហា ២០០២ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០២ ថវិការ ៣៦៦ លាន យេន<br>កុម្ភៈ ២០០៣ : បញ្ជូនក្រុមបេសកកម្មត្រួតពិនិត្យគំរោង<br>មិថុនា ២០០៣ : បញ្ជូននិស្សិតទៅសិក្សានៅជប៉ុនលើកទី៣ ( ឆ្នាំសារពើពន្ធ ២០០២)<br>២៥ មិថុនា ២០០៣ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០៣ ( ថវិការ ៥៧ លាន យេន សំរាប់ចំណាយនៅកម្ពុជា)<br>១៨ ឧសភា ២០០៤ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០៤<br>មិថុនា ២០០៤ : ការបញ្ជូននិស្សិតទៅសិក្សានៅជប៉ុនលើកទី៤ ( ឆ្នាំសារពើពន្ធ ២០០៣)<br>មិថុនា ២០០៥ : ការបញ្ជូននិស្សិតទៅសិក្សានៅជប៉ុនលើកទី៤ ( ឆ្នាំសារពើពន្ធ ២០០៤)<br>២៩ សីហា ២០០៥ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០៥<br>១២ មិថុនា ២០០៦ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ២០០៦<br>កក្កដា ២០០៦ : ការបញ្ជូននិស្សិតទៅសិក្សានៅជប៉ុនលើកទី៥ ( ឆ្នាំសារពើពន្ធ ២០០៥) |
| ក្រុមហ៊ុនប្រឹក្សាយោបល់ : Japan International Cooperation Center (JICE) |

## ( ២) គំរោងស្តារប្រព័ន្ធស្រោចស្រពស្រុកកណ្តាលស្ទឹងនៅអាងទំនាបព្រែកត្នោត

គោលបំណងសំខាន់របស់គំរោងនេះ គឺការផ្តល់ទឹកស្រោចស្រពគ្រប់គ្រាន់សំរាប់តំបន់កណ្តាលស្ទឹង តាមរយៈការស្តារឧបករណ៍ស្រោចស្រពឡើងវិញ រួមមានទាំង ឧបករណ៍និយ័តទឹក ប្រព័ន្ធស្តុក ប្រលាយមេ និង ប្រលាយបង្ហូរ និង ប្រព័ន្ធទាក់ទងផ្សេងៗទៀត ។ នៅក្នុងរយះពេលមធ្យម និង វែង គំរោង នឹងរួមចំណែកក្នុងការបង្កើនផលិតភាពកសិកម្ម នៅតំបន់ដែលគំរោងគ្របដណ្តប់ ។ ក្រសួងធនធានទឹក និង ឧតុនិយម គឺជាសមភាគីរបស់គំរោង ។

| |
|---|
| **ទីតាំងគំរោង :** កណ្តាលស្ទឹង/កណ្តាល |
| **ព័តិមានទាក់ទង :**<br>វិច្ឆិកា ២០០២ : ក្រុមបេសកកម្មសិក្សាដំបូង B/D<br>វិច្ឆិកា ២០០៤ : ក្រុមបេសកកម្មសិក្សាដំបូងលំអិត D・B/D<br>១៨ មករា ២០០៥ : ចុះហត្ថលេខាលើឯកសារកំនត់ទូត E/N (44mil. Yens)<br>១០ មិថុនា ២០០៥ : ចុះហត្ថលេខាលើឯកសារកំនត់ទូត ( ១៧៤ លានយេន) |
| ក្រុមហ៊ុនប្រឹក្សា : Nippon Koei Co., Ltd. |
| ក្រុមហ៊ុនសាងសង់ : MAEDA Corporation |

## (៣) គំរោងកែលំអឡើងវិញផ្លូវជាតិលេខ១ (កំណាត់ភ្នំពេញ-អ្នកលឿង)

អាស្រ័យលើតំរូវការដ៏ទទូចរបស់រាជរដ្ឋាភិបាលកម្ពុជាផ្អែកលើសារៈសំខាន់នៃគំរោងនេះ រដ្ឋាភិបាលជប៉ុន បានសំរេចសហការក្នុងគំរោងនេះ ។ គំរោង នឹងផ្តល់ជាកំនាត់ផ្លូវសំខាន់មួយសំរាប់ភ្ជាប់ក្រុងបាងកក ភ្នំពេញ និង ហូជីមិញ ។ ផ្អែកលើលទ្ធផលនៃការសិក្សាអភិវឌ្ឍន៍របស់គំរោងដែលបានបញ្ចប់នៅខែមិនា ឆ្នាំ ២០០៣ ធ្វើដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មានគ្រួសារប្រហែលជា ១៨០០ ត្រូវបានប៉ះពាល់ ដោយសារគំរោង ដូចជា ការរុះរើទីលំនៅដែលស្ថិតនៅក្នុងតំបន់គំរោង និង ការរំកិលថយ ក្រោយចេញផុតពីគំរោង ។ មុនពេលចាប់ផ្តើមការសិក្សាពីគ្រោងមូលដ្ឋានរបស់គំរោង ទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន បានបញ្ជូនក្រុមបេសកកម្មវិភាគពីផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន ដើម្បីជំរុញអោយរាជរដ្ឋាភិបាលបង្កើត ផែនការសកម្មភាពសំរាប់ការតាំងទីលំនៅឡើងវិញដ៏ត្រឹមត្រូវមួយ និង អនុវត្តន៍និតិវិធីរុះរើ និង តាំងទីលំនៅថ្មីសំរាប់ គ្រួសារដែលប៉ះពាល់ដោយគំរោងប្រកបដោយប្រសិទ្ធភាព តំលាភាព និង មានការជឿជាក់ ។ ក្រសួងសាធារណការ និង ដឹកជញ្ជូនគឺជាសមភាគីនៃគំរោង ។

| |
|---|
| **ទីតាំងគំរោង :** ភ្នំពេញ និង កណ្តាល |
| **ព័ត៌មានទាក់ទង :**<br>មិនា ២០០៣ : បញ្ចប់ការសិក្សាអភិវឌ្ឍន៍ដែលទាក់ទងនឹងគំរោង<br>កក្កដា ២០០៣ : បញ្ជូនក្រុមបេសកកម្មវិភាគពីផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម របស់គំរោង<br>ធ្នូ ២០០៣ : បញ្ចប់បេសកកម្មរបស់ក្រុមវិភាគ<br>កុម្ភៈ ២០០៤ : បញ្ជូនក្រុមបេសកកម្មសិក្សាពីគ្រោងជាមូលដ្ឋានរបស់គំរោង<br>មករា ២០០៥ : បញ្ជូនក្រុមបេសកកម្មវិភាគពីផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម របស់គំរោង<br>មិនា ២០០៥ : បញ្ជូនក្រុមបេសកកម្មវិភាគពីផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម របស់គំរោង (លើកទី២)<br>មិថុនា ២០០៥ : ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀងលើកទី១ សំរាប់ការសាងសង់ស្ពានចំនួនពីរលើកំណាត់ផ្លូវដែលត្រូវស្តារ (៧៨៦ លានយេន)<br>០៦ ធ្នូ ២០០៥: បើកការដ្ឋានសាងសង់ស្ពានសំខាន់លេខ២ និងលេខ៣ នៅតាមបណ្តោយផ្លូវ<br>មិថុនា ២០០៦ : ចុះហត្ថលេខាលើកំនត់ទុតព្រមព្រៀងលើកទី២ (៤ ៧៤៦ លានយេន) |
| ក្រុមហ៊ុនប្រឹក្សាយោបល់: Katahira & Engineers Inc. and CTI Engineering International Co.,Ltd. (JV)<br>ក្រុមហ៊ុនសាងសង់ : OBAYASHI Corperation (សង់ស្ពានពីរ) |

## (៤) គំរោងកសាងសាលាបឋមសិក្សានៅរាជធានីភ្នំពេញ (ដំណាក់កាលទី២)

ដើម្បីកាត់បន្ថយនូវចំនួនដ៏ច្រើនលើសលុបរបស់សិស្សធៀបនឹងចំនួនថ្នាក់រៀនដែលមាននៅតាមសាលាបឋមសិក្សា នៅទីក្រុងភ្នំពេញ គំរោងកសាងសាលាបឋមសិក្សាជំហានទី២ ត្រូវបានផ្តួចផ្តើមឡើង ។ គំរោងនេះផ្តោតជាសំខាន់លើការកែលំអបរិយាកាសសិក្សាសំរាប់សិស្ស តាមរយៈការផ្គត់ផ្គង់ថ្នាក់រៀនបន្ថែមដល់សាលាបឋមសិក្សាចំនួន ៥ នៅទីក្រុងភ្នំពេញ ។ គំរោងនេះគ្រោងនឹងចាប់ផ្តើមនៅឆ្នាំ ២០០៦ ។ ក្រសួងអប់រំ យុវជន និង កីឡា និង រាជធានីភ្នំពេញ គឺជាសមភាគីរបស់គំរោង ។

**ទីតាំងគំរោង :** ភ្នំពេញ

**ព័ត៌មានទាក់ទងនឹងគំរោង :**
មករា-កុម្ភៈ ២០០៥ : ក្រុមបេសកម្មសិក្សាគ្រោងជាមូលដ្ឋាន
ឧសភា-មិថុនា ២០០៥ : ក្រុមបេសកម្មពង្រាងគ្រោងជាមូលដ្ឋាន
២៩ សីហា ២០០៥ : ចុះហត្ថលេខាលើកំនត់ទុតព្រមព្រៀង (៥១០ លាន យេន)

ក្រុមហ៊ុនប្រឹក្សាយោបល់ : Yachiyo Engineering
ក្រុមហ៊ុនសាងសង់ : Konoike Cooperation

## (៥) គំរោងសំរាប់ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទសំរាប់ខេត្តកំពង់ចាម

ផ្អែកលើលទ្ធផលដែលទទួលបាន តាមរយៈការសិក្សាអំពីការអភិវឌ្ឍន៍ទឹកដែលស្ថិតនៅក្រោមដីនៅតំបន់កណ្តាលរបស់កម្ពុជា ដែលបានធ្វើក្នុងរវាងឆ្នាំ ២០០០ និង ២០០២ ការជីក និងធ្វើអណ្តូងស្នប់ដោយដៃ នឹងត្រូវបានគេធ្វើនៅក្នុងខេត្តកំពង់ចាម ដើម្បីបំរើអោយការផ្គត់ផ្គង់ទឹកស្អាត ។ ខេត្តទទួលបានអាទិភាពខ្ពស់បន្ទាប់ពីតំបន់ជាយក្រុងភ្នំពេញ នៅក្នុងការសិក្សានោះ ។ ការសិក្សាគ្រោងលំអិតរបស់គំរោងបានចាប់ផ្តើមនៅខែ មិថុនា ឆ្នាំ ២០០៥ ។ ក្រសួងអភិវឌ្ឍន៍ជនបទ គឺជាសមភាគីរបស់គំរោង ។

**ទីតាំងគំរោង :** កំពង់ចាម

**ព័ត៌មានទាក់ទងនឹងគំរោង :**
តុលា ២០០៤ : ក្រុមបេសកម្មសិក្សាគ្រោងជាមូលដ្ឋានរបស់គំរោង
កុម្ភៈ ២០០៥ : ក្រុមសិក្សាពង្រាងការសិក្សាគ្រោងជាមូលដ្ឋាន
មិថុនា ២០០៥ : ក្រុមបេសកម្មសិក្សាគ្រោងលំអិតរបស់គំរោង
១០ មិថុនា ២០០៥ : ចុះហត្ថលេខាលើឯកសារកំនត់ទូត (៤៣៤ លានយេន)
១២ មិថុនា ២០០៦ : ចុះហត្ថលេខាលើឯកសារកំនត់ទូតចុងក្រោយ (៤៣១ លានយេន)

ក្រុមហ៊ុនប្រឹក្សាយោបល់ :Kokusai Kogyo Co., LTD.

## (៦) គំរោងអគ្គិសនីជនបទតាមរយៈវារីអគ្គិសនីធុនតូចនៅតំបន់ដាច់ស្រយាលនៅខេត្តមណ្ឌលគិរី

គោលបំណងរបស់គំរោង គឺការស្ថាបនាវារីអគ្គិសនី ធុនតូចចំនួនបីនៅខេត្តមណ្ឌលគិរី ។ វារីអគ្គិសនីទាំងនោះនឹងអាចផ្តល់ថាមពលអគ្គិសនីគ្រប់គ្រាន់សំរាប់ការប្រើប្រាស់របស់ប្រជាជនដែលនៅក្នុងខេត្ត ។ គំរោង ត្រូវបានរំពឹងទុកថា នឹងបញ្ចប់នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៧ ។ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល គឺជាសមភាគីរបស់គំរោង ។ ការសិក្សាគ្រោងជាមូលដ្ឋាននៃគំរោងបានបញ្ចប់រួចហើយ ។

**ទីតាំងគំរោង :** មណ្ឌលគិរី

**ព័ត៌មានទាក់ទងនឹងគំរោង :**
ធ្នូ ២០០៤ : ក្រុមបេសកម្មសិក្សាគ្រោងជាមូលដ្ឋាននៃគំរោង
កញ្ញា ២៩-២០០៥: ចុះហត្ថលេខាលើកំនត់ទូតព្រមព្រៀង (ការសិក្សាវិស្វកម្មលំអិត-៤១ លាន យេន)
១២ មិថុនា ២០០៦ : ចុះហត្ថលេខាលើកំនត់ទុតព្រមព្រៀង (១ ០៦៦ លានយេន)

ក្រុមហ៊ុនប្រឹក្សាយោបល់ : Nippon Koei Co., Ltd. and J-Power Co., Ltd (JV)

## (៧) គំរោងស្តារស្ពាននៅតាមផ្លូវជាតិសំខាន់៧ឡើងវិញ

គោលបំណងរបស់គំរោង គឺការស្តារឡើងវិញនូវស្ពានដែលមានទីតាំងនៅតាមបណ្តោយផ្លូវសំខាន់៧ នៅទីក្រុង ភ្នំពេញ ខេត្តកណ្តាល និង តាកែវ ដោយផ្តោតលើ : (១) កសាងឡើងវិញស្ពានតាខ្មៅទីពីរ ស្ពានព្រែកហូរ និង ស្ពានស្លាគូ (២) ការស្តារឡើងវិញនូវស្ពានជ្រោយចង្វារ ។

| |
|---|
| **ទីតាំងគំរោង :** តាខ្មៅ/ភ្នំពេញ និង កណ្តាល |
| **ព័តិមានទាក់ទងនឹងគំរោង :**<br>កុម្ភៈ-ធ្នូ ២០០៤ : ក្រុមបេសកម្មសិក្សាគ្រោងជាមូលដ្ឋានរបស់គំរោង<br>១៣ ធ្នូ ២០០៤ : ចុះហត្ថលេខាលើកំនត់ទុតព្រមព្រៀងនៃគំរោង (ថវិការ ១៥០ លានយេន) (កែលំអឡើងវិញស្ពានជ្រោយចង្វា)<br>១០ មិថុនា ២០០៥: ចុះហត្ថលេខាលើកំនត់ប្រមព្រៀង (ថវិកា ៨៤៤ លាន យេន សំរាប់ការសាងសង់ស្ពានទាំងបីនៅតាខ្មៅ ព្រែកហូរ និង ស្លាគូ)<br>១២ មករា ២០០៦ : បើកការដ្ឋានសាងសង់របស់គំរោង |
| ក្រុមហ៊ុនប្រឹក្សាយោបល់ : Katahira Engineering Co., LTD.<br>ក្រុមហ៊ុនសាងសង់ :<br>OBAYASHI Corporation ¬ស្ពានជ្រោយចង្វា)<br>MAEDA Corporation (ស្ពានបីផ្សេងទៀត) |

## (៨) គំរោងកែលំអមន្ទីរពេទ្យមង្គលបុរីនៅខេត្តបន្ទាយមានជ័យ

មន្ទីរពេទ្យត្រូវបានសាងសង់ និងដាក់ដំណើរការដោយមានការ សហការជាមួយរដ្ឋាភិបាលជប៉ុន សំដៅសងដល់ការខូចខាតដែល កើតមានដោយសារសង្គ្រាមលោកលើកទី ២ ។ គោលបំណងរបស់ គំរោងគឺកែលំអអាគារពេទ្យចាស់ និងសំភារៈប្រើប្រាស់របស់មន្ទីរពេទ្យដែលទ្រុឌទ្រោមប្រើលែងបាន ។ គំរោងនេះក៏ផ្តោតផងដែរ លើការបង្កើនសមត្ថភាពសេវាសុខាភិបាល និងវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ ។

| |
|---|
| **ទីតាំងគំរោង :** មង្គលបុរី |
| **ព័តមានដែលទាក់ទង :**<br>វិច្ឆិកា ២០០៤ មិថុនា ២០០៥: ក្រុមបេសកម្មរៀបចំសិក្សាគំរោង ជាមូលដ្ឋាន<br>២៩ សីហា ២០០៥ : ចុះហត្ថលេខាលើកំនត់ហេតុព្រមព្រៀងទូត (695mil.Yen) |
| ក្រុមហ៊ុនទីប្រឹក្សា : Azusa sekkei co.,LTD<br>ក្រុមហ៊ុនសាងសង់ : Konoike Corporation |

## (៩) គំរោងជុលជុលឡើងវិញមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម

កំពង់ចាមគឺជាទីក្រុងដែលជាប់នឹងទីក្រុងភ្នំពេញ និងមានប្រជាជនដល់ទៅ ១,៦១ លាននាក់ ។ គំរោងសំដៅចូលរួមចំណែកក្នុងការធ្វើអោយប្រសើរឡើងវិញនូវសេវាសុខភាពស្ថាប័ន និងបរិក្ខារវេជ្ជសាស្ត្រ របស់មន្ទីរពេទ្យនេះ ។ គំរោងនឹងស្ថាបនាឡើងវិញនូវអាគារសង្គ្រោះបន្ទាន់មួយដែលចាស់ទ្រុឌទ្រោម និងអាគារកោសល្យវេជ្ជសាស្ត្រ (វះកាត់) ។

| |
|---|
| **ទីតាំងគំរោង :** កំពង់ចាម |
| **ព័តមានដែលទាក់ទង :**<br>មេសា-ឧសភា ២០០៦: ក្រុមបេសកម្មរៀបចំសិក្សាគំរោង ជាមូលដ្ឋាន |
| ក្រុមហ៊ុនទីប្រឹក្សា : Azusa sekkei co.,LTD<br>ក្រុមហ៊ុនសាងសង់ : N/A |

**(១០) គំរោងការពារទឹកជំនន់ និង ស្តារឡើងវិញនូវប្រព័ន្ធលូសំរាប់ទីក្រុងភ្នំពេញ ដំណាក់កាលទី ២**

គំរោងនេះគឺជាសំណើបន្តពីគំរោងក្នុងដំណាក់កាលទីមួយដែលបានបញ្ចប់រួចហើយ ។

| |
|---|
| **ទីតាំងគំរោង :** ទីក្រុងភ្នំពេញ |
| **ព្រឹត្តិការណ៍សំខាន់ៗ :**<br>មករា-កញ្ញា ២០០៦ : ការសិក្សាគ្រោងការដំបូង<br>១១ មករា-២២ កុម្ភៈ ២០០៦ : ទស្សនកិច្ចដំបូងរបស់ក្រុមសិក្សា<br>សីហា ២០០៦ : ទស្សនកិច្ចលើកទី ២ របស់ក្រុមសិក្សា<br>ពាក់កណ្តាលខែកញ្ញា ២០០៦ : របាយការណ៍សំរេច |
| ក្រុមហ៊ុនទីប្រឹក្សា : CTI Engineering International Co., LTD<br>សហការ ជាមួយ Nippon Koei Co., LTD |

សំណើដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគំរោងនេះ រួមមាន : (ក) ការស្ថាបនាច្រាំងថ្មតាមបណ្តោយទន្លេសាប (ខ) ការស្តារឡើងវិញនូវប្រព័ន្ធលូនៃតំបន់ផ្សារថ្មី (គ) ការស្តារឡើងវិញនូវប្រព័ន្ធលូនៃតំបន់រាជវាំង និង សារៈមន្ទីរជាតិ (ឃ) ការស្តារប្រព័ន្ធលូតាមផ្លូវ និង ធ្វើផ្លូវឡើងវិញនៅអាងបឹងត្របែក និង តំបន់ប្រសព្វ (ង) ការស្តារឡើងវិញនូវប្រព័ន្ធលូនៃតំបន់វត្តភ្នំ ។ ដើម្បីដំណើរការគំរោងនេះ រដ្ឋាភិបាលជប៉ុនសំរេចធ្វើការសិក្សាគ្រោងការដំបូងមួយសំរាប់ (ក) បញ្ជាក់ពីតំរូវការគំរោង (ខ) សំរបសំរួលគំរោងទៅនឹងផែនការអភិវឌ្ឍន៍ជាតិ តំបន់ និង វិស័យ (គ) វាយតំលៃពីលទ្ធភាពបច្ចេកទេសនៃគំរោង (ឃ) ស្ថាបនាគ្រោងជាមូលដ្ឋាននៃគំរោង និង (ង) ធ្វើការប៉ាន់ស្មានតំលៃ និង កាលវិភាគគំរោង ។ នាយកដ្ឋានសាធារណការរបស់សាលាក្រុងភ្នំពេញ គឺជាសមភាគីនៃគំរោង ។

**(១១) គំរោងពង្រឹងឧបករណ៍សុវត្ថិភាពនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ និង ភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា**

| |
|---|
| **ទីតាំងគំរោង :** ក្រុងព្រះសីហនុ និង ក្រុងភ្នំពេញ |
| **ព្រឹត្តការណ៍សំខាន់ៗ :**<br>មករា ២០០៦ : ការសិក្សាគ្រោងការដំបូងចាប់ផ្តើម<br>២០ មករា ២០០៦ : ចុះហត្ថលេខាលើសេចក្តីពិភាក្សានៃគំរោង<br>កក្កដា ២០០៦ : របាយការណ៍សំរេចការសិក្សាគ្រោងការដំបូង |
| ក្រុមហ៊ុនទីប្រឹក្សា : |

ឆ្លើយតបទៅនឹងសំណូមពររបស់រាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលជប៉ុន សំរេចធ្វើការសិក្សាគ្រោងការជាមូលដ្ឋាន សំរាប់គំរោងខាងលើ ក្នុងគោលបំណងពង្រឹងឧបករណ៍សុវត្ថិភាពទប់ទល់ទៅ និងប្រឆាំងតបទៅនឹងអំពើភេរវកម្ម និង ពង្រឹងសកម្មភាពពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា ។

គំរោងផ្តោតជាសំខាន់លើកំពង់ផែភ្នំពេញ និង សីហនុ របស់កម្ពុជា ។ គោលបំណងនៃការសិក្សា គឺ : (ក) បញ្ជាក់ពីតំរូវការរបស់គំរោង (ខ) សំរបសំរួលគំរោងទៅនឹងផែនការអភិវឌ្ឍន៍ជាតិ តំបន់ និងវិស័យ (គ) វាយតំលៃលទ្ធភាពបច្ចេកទេសនៃគំរោង (ឃ) ធ្វើពង្រាងគ្រោងមូលដ្ឋាននៃគំរោង និង (ង) ប៉ាន់ស្មានពីតំលៃគំរាង ។

ក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់កម្ពុជា គឺជាសមភាគីនៃគំរោង ។ ចំពោះការអនុវត្តគំរោងភាគីកម្ពុជា រួមមាន កំពង់ផែស្វយ័តក្រុងព្រះសីហនុ និង ភ្នំពេញ និង ទីចាត់ការគយ និងរដ្ឋករ ។

## ១០. កម្មវិធីពង្រឹងសហគមន៍

កម្មវិធីនេះ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងទំរង់ជំនួយថ្មីរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ។ កម្មវិធី ផ្តោតជាសំខាន់ទៅលើការលើកកំពស់ជីវភាព និង សុខមាលភាពរស់នៅរបស់ប្រជាជននៅតាមតំបន់មូលដ្ឋានរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ តាមរយៈទំរង់ជំនួយថ្មីនេះ គំរោងគំរូមួយដោយមានការគាំទ្រពីរដ្ឋាភិបាលទទួលជំនួយ និង ត្រូវអនុវត្តរួមគ្នាដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និង អង្គការក្រៅរដ្ឋាភិបាលដែលជាស្ថាប័នអនុវត្តគំរោងដ៏សំខាន់នៅកំរិតមូលដ្ឋាន ។ ចាប់តាំងពីឆ្នាំ ២០០៣ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនបានសហការអនុវត្តគំរោងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនៅតាមមូលដ្ឋានដែលកំពុងធ្វើការក្នុងទស្សនៈដូចគ្នាទៅនឹងកម្មវិធីសហប្រតិបត្តិការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនដែលបានសង្ខេបនៅទំព័រទី៣ និងទី៤ នៃឯកសារនេះ ។

### (១) គំរោងរបេងដូតស៍សហគម និង របេងហ៊ីវនៅខេត្តស្វាយរៀង និង កំពត

| |
|---|
| ទីតាំងគំរោង : ខេត្តស្វាយរៀង និង កំពត |
| រយៈពេលនៃគំរោង : កក្កដា ២០០៦-មិថុនា ២០០៩ |

គំរោងនេះអនុវត្តន៍ដោយអង្គការក្រៅរដ្ឋាភិបាលដែលបំរើការនៅមូលដ្ឋានមួយមានឈ្មោះថា គណកម្មការសុខភាពកម្ពុជា ។ គោលដៅគំរោងគឺបង្កើនការផ្តល់ថ្នាំព្យាបាលរោគរបេងតាមវិធីសាស្ត្រ DOTS ជាមួយគ្នាផងដែរសំដៅអ្នកមានផ្ទុកមេរោគហ៊ីវ ដែលមានជំងឺរបេង នៅខេត្តស្វាយរៀង និង កំពត ។ គំរោងធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងគំរោងប្រឆាំងជំងឺរបេងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺរបេង និង រោគសើស្បែក កម្មវិធីជាតិប្រយុទ្ធប្រឆាំងជំងឺរបេង កម្មវិធីជាតិប្រឆាំងនឹងជំងឺអេដស៍ នៅតាមស្រុកប្រតិបត្តិ ។

### (២) គំរោងពង្រឹងជីវភាពរស់នៅរបស់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវ ដំណាក់កាលទី២ (ILFARM-Tramkok II)

| |
|---|
| ទីតាំងគំរោង : ស្រុកត្រាំកក់ខេត្តតាកែវ |
| រយៈពេលនៃគំរោង : កក្កដា ២០០៦-មិថុនា ២០០៩ |
| ដៃគូ : CEDAC |

គំរោងត្រូវបានបង្កើតឡើងដោយផ្អែកលើសមិទ្ធផលបទពិសោធន៍ និង មេរៀនពីគំរោងមុន (ILFARM-Tramkok I) ដែលបានអនុវត្តពីឆ្នាំ ២០០៣ ដល់ ២០០៥ ដោយការសហការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនជាមួយនឹង មជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍន៍កសិកម្ម (CEDAC) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយធ្វើការជំនាញខាងផ្នែកកសិកម្ម និង អភិវឌ្ឍន៍ជនបទ ។ គោលបំណងសំខាន់របស់គំរោងគឺការពង្រឹងជីវភាពរស់នៅរបស់កសិករ

ក្រីក្រតាមរយៈវិធីសាស្ត្រពង្រីកកសិកម្មដែលអនុវត្តដោយកសិករខ្លួនឯង ពង្រឹងសេវាកម្មធ្វើទីផ្សារ និង ហិរញ្ញវត្ថុ តាមវិធីសាស្ត្រជាក់ស្តែងក្នុងការបង្កើតសមាគមន៍កសិករ មគ្គុទេស និង ការទទួលយក បច្ចេកទេសកសិកម្មថ្មីដូចជា SRI, ការធ្វើកសិកម្មដោយមានការគិតគូរពីប្រព័ន្ធជីវសាស្ត្រដែលពាក់ព័ន្ធ ។ល។ និង ការសហការដ៏ស្អិតរមួតរវាង មន្ទីរកសិកម្មខេត្ត អាជ្ញាធរពាក់ព័ន្ធ និង ប្រជាជននៅតាមសហគមន៍ ។

## ១១. កម្មវិធីជាដៃគូសហប្រតិបត្តិការ

កម្មវិធី គឺជាកម្មវិធីសហប្រតិបត្តិការថ្មីសំដៅអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ច នៅកំរិតមូលដ្ឋាន ជាពិសេស កម្មវិធីនេះបានបង្កើតឡើងសំរាប់ដៃគូអភិវឌ្ឍន៍នៅជប៉ុន ដែលមានដូចជា អង្គការក្រៅរដ្ឋាភិបាល មហាវិទ្យាល័យ រដ្ឋាភិបាលតាមមូលដ្ឋាន នៅទីនោះជាដើម ។ គមរោងដែលអនុវត្តនៅក្រោមរូបភាពរបៀបនេះ មានបីប្រភេទ : ជាដៃគូ ជាការគាំទ្រ និង ជាការសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

### (១) គំរោងថែទាំសុខភាពបឋមនៅតំបន់ជនបទរបស់កម្ពុជា

| |
|---|
| **រយៈពេលនៃគំរោង** : មករា ២០០៥-ធ្នូ ២០០៧ |
| **ទីតាំងគំរោង** : កំពង់ចាម |

គំរោងនេះកំពុងតែអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុន ឈ្មោះ SHARE ជាមួយនឹងការសហការនឹងក្រសួងសុខាភិបាល និង នាយកដ្ឋានប្រតិបត្តិសុខភាពស្រុក របស់ស្រុកស្រីសន្ធរ និង ស្រុកកងមាស ។ គោលបំណងសំខាន់របស់គំរោង គឺជំរុញការចូលរួមរបស់ប្រជាជននៅតាមជនបទ ក្នុងសកម្មភាពសុខភាពដើម្បីអោយពួកគាត់អាចប្រើប្រាស់ចំណេះដឹងដែលពួកគាត់ទទួលបាន ក្នុងការដោះស្រាយបញ្ហាសុខភាព ជាមួយនឹងមជ្ឈមណ្ឌលសុខភាពដែលមានក្នុងតំបន់ ។

### (២) គំរោងលើកកំពស់គុណភាពការអប់រំនៅថ្នាក់បឋមសិក្សាតាមរយៈសកម្មភាពបណ្ណាល័យ

| |
|---|
| **រយៈពេលនៃគំរោង** : ឧសភា ២០០៤-មេសា ២០០៧ |
| **ទីតាំងគំរោង** : បន្ទាយមានជ័យ |

អង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុន ឈ្មោះ SVA (Shanti Volunteer Association) អនុវត្តគំរោងនេះនៅខេត្តបន្ទាយមានជ័យ ។ គោលបំណងរបស់គំរោង គឺបង្កើតទិដ្ឋភាពពីរតាមរយៈការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវបណ្ណាល័យ និង ការពង្រឹងការប្រើប្រាស់បណ្ណាល័យ ។ ទិដ្ឋភាពទីមួយ គឺការពង្រឹងសមត្ថភាពវាក្យសព្ទ លំហាត់គំនិត និង មនោរម្មណ៍សំរាប់កុមារ ។ ទិដ្ឋភាពទីពីរ គឺការយកចិត្តទុកដាក់លើសមត្ថភាពរបស់គ្រូគ្រប់គ្រងបណ្ណាល័យ ការប្រើប្រាស់ទូលំទូលាយនៃឯកសារបង្រៀន និង ការចូលរួមពីសំណាក់ប្រជាពលរដ្ឋនៅក្នុងការអប់រំបឋមសិក្សា ។

(៣) គំរោងពង្រឹងកម្មវិធី និង សៀវភៅសំរាប់គ្រូលើមុខវិជ្ជាអប់រំកាយសំរាប់សាលាបឋមសិក្សាក្នុងកម្ពុជា

អង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុនមួយមានឈ្មោះថា Heart of Gold (HG) ជាអ្នកអនុវត្តគំរោងនៅប្រទេសកម្ពុជា ។ គោលបំណងសំខាន់របស់គំរោងគឺការផ្តល់យោបល់ និង មតិក្នុងការរៀបចំសៀវភៅគ្រូលើមុខវិជ្ជាកាយសិក្សានៅថ្នាក់បឋមសិក្សា និង បន្ទាប់មកធ្វើការណែនាំអំពី សៀវភៅនេះដល់ក្រសួងអប់រំ យុវជន និង កីឡា ។

**រយៈពេលនៃគំរោង** : កុម្ភៈ ២០០៦-កក្កដា ២០០៨
**ទីតាំងគំរោង** : ទូទាំងកម្ពុជា

## ១២ - កម្មវិធីភាពជាដៃគូនៅតំរិតសហគម

(១) គំរោងពង្រឹងការគ្រប់គ្រងសាលាបឋមសិក្សានៅខេត្តសៀមរាប

បណ្តាញក្រុមអ្នកដើម្បីសន្តិភាពរបស់ខេត្តហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុន ជាអ្នកអនុវត្តន៏គំរោងនេះនៅស្រុកពួកខេត្តសៀមរាប ។ គោលបំណងសំខាន់របស់គំរោងគឺពង្រឹងការគ្រប់គ្រងរបស់សាលា តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំដល់នាយកសាលាទាំងឡាយរបស់កំរងសាលាសសរស្តំា ។ បណ្តាញក្រុមអ្នកដើម្បីសន្តិភាពបានបញ្ជូន អ្នកជំនាញពីសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ាដើម្បីពង្រឹងការគ្រប់ គ្រងសាលាតាមរយៈការណែនាំអំពីគោលការណ៏នៃភាពជាអ្នកដឹកនាំដល់កំរងសាលាសសរស្តំានៅខេត្តសៀមរាប ។

**រយៈពេលនៃគំរោង** : ២០០៥-២០០៨
**ទីតាំងគំរោង** : សៀមរាប

(២) គំរោងអភិវឌ្ឍន៏ធនធានមនុស្សខាងការគ្រប់គ្រងបរិស្ថាន

គំរោងនេះត្រូវបានអនុវត្តន៏ដោយរដ្ឋភិបាលមូលដ្ឋាននៃខេត្ត កាហ្គាវ៉ា ក្នុងរូបភាពគំរោងកិច្ចសហប្រត្តិបត្តិការអន្តរជាតិ ។ គោលបំណងសំខាន់របស់គំរោង គឺការផ្ទេរបច្ចេកទេស វិធីសាស្ត្រ និង បទពិសោធន៏ ដែលខេត្ត កាហ្គាវ៉ា ដល់ធនធានមនុស្សកម្ពុជានៅក្នុងវិស័យបរិស្ថាន ។

**រយៈពេលនៃគំរោង** : កញ្ញា ២០០៦-មិនា ២០០៩
**ទីតាំងគំរោង** : ទូទាំងប្រទេស

# ១២-ព័ត៌មាន និង ស្ថិតិមូលដ្ឋានមួយចំនួនអំពីកម្ពុជា

| | | | |
|---|---|---|---|
| **រដ្ឋបាលគ្រប់គ្រង** | | | |
| ១ | ឈ្មោះប្រទេស | ព្រះរាជាណាចក្រកម្ពុជា | |
| ២ | ទីក្រុងសំខាន់ | ភ្នំពេញ | |
| ៣ | ចំនួនក្រុង | ៤ ក្រុង | |
| ៤ | ចំនួនខេត្ត | ២០ ខេត្ត | |
| **ប្រជាជន** | | ១៩៩៨ | ២០០៤ |
| ៥ | ប្រជាជន | ១១ ៤៣៧ ៦៥៦ [1] | ១៣, ៥ លាន [2] |
| ៦ | អត្រាកំនើនប្រជាជន (គិតជាភាគរយ) | ២.៥ [1] | ២.១ (១៩៩៨-២០០៤) [2] |
| ៧ | ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការេ | ៧៦ [1] | ៧៥[2] |
| ៨ | ចំនួនប្រជាជននៅទីក្រុងភ្នំពេញ | ៩៩៩ ៨០៤[1] | ១ ១៨៤ ៩៤៥ [2] |
| **សាសនា** | | ឆ្នាំ ២០០១ | |
| ៩ | ពុទ្ធសាសនា | ៩៦%[4] | |
| ១០ | គ្រិស្តសាសនា | ១%[4] | |
| ១១ | មូស្លីម/អុិស្លាម | ២%[4] | |
| ១២ | សាសនាដទៃទៀត | ១%[4] | |
| ***ភូមិសាស្ត្រ*** | | | |
| ១៣ | ទំហំ | ១៨១ ០៣៥ គីឡូម៉ែត្រការ៉េ | |
| **សីតុណ្ហភាព** | | | |
| ១៤ | សីតុណ្ហភាពអតិបរិមានៅទីក្រុងភ្នំពេញ (២០០៤) | ២៨.៥ °C [6] | |
| ១៥ | សំណើមជាមធ្យមនៅទីក្រុងភ្នំពេញ (២០០២) | ៧៦.៨% [6] | |
| ១៦ | រដូវវស្សា | ឧសភា ដល់ វិច្ឆកា | |
| ១៧ | រដូវប្រាំង | ធ្នូ ដល់ មេសា | |
| ១៨ | គិតទឹកភ្លៀងមធ្យមនៅកម្ពុជា (ជាមធ្យម ២០០៤) | ១៧២ ស.ម [2] | |
| **រូបិយវត្ថុ** | | | |
| ១៩ | រូបិយវត្ថុជាតិ | រៀល | |
| ២០ | អត្រាប្តូរប្រាក់រៀល (ជាមធ្យម) | ១US$=៤ ១០២រៀល [3] ១US$=១១៦.៣១ យេន [3] | |
| **ស្ថានភាពសេដ្ឋកិច្ច** | | ២០០០ | ២០០៤ |
| ២១ | ផលិតផលក្នុងស្រុកសរុបតាមតំលៃបច្ចុប្បន្ន | ៣៦៥១ លាន US$[2] | ៤៤៥០ លាន US$ [2] |
| ២២ | ផលិតផលក្នុងស្រុកសរុប/ម្នាក់ | ២៨៨ US$[2] | ៣២៨ US$[2] |

| | | | |
|---|---|---|---|
| ២៣ | ស្ថានភាពចំនូល និង ចំនាយជាតិ | ២០០៤ | |
| | | ចំនូលសរុប<br>២ ១២៦.៧ កោដិរៀល [(2)] | ចំណាយសរុប<br>២ ៩៧០.២កោដិរៀល [(2)] |
| ២៤ | ស្ថានភាពពាណិជ្ជកម្មអន្តរជាតិជាមួយជប៉ុន | ២០០៤ | |
| | | នាំចេញ<br>៨ ៦៣៥ លានយេន [(5)] | នាំចូល<br>១០ ៧៨៥ លានយេន [(5)] |
| ២៥ | ជំនួយជប៉ុនសំរាប់កម្ពុជា | - ជំនួយឥតសំណង : ១០២.២ កោដិយេន( សរុប១៩៩២-២០០៤) [(5)]<br>- កិច្ចសហប្រតិបត្តិការបច្ចេកទេស : ៣៤.៧ កោដិយេន ( សរុប ១៩៩២-២០០៤ ) [(5)]<br>- កំចី : ១៣.០ កោដិយេន ( សរុប ១៩៩២-២០០៤) [(5)] | |

កំនត់សំគាល់ : [P] Preliminary estimates, 1 billion = a thousand millions

ប្រភព:

(1) NIS, MoP, July 1999. General Population Census of Cambodia 1998
(2) NIS, MoP, October 2005. Cambodia Statistical Year Book 2005
(3) The Cambodia Daily, December 01, 2006
(4) Department of Multi-Religions, Ministry of Culture and Religion Affaire. Statistic on Multi-Religions in Cambodia2001(Khmer)
(5) Government of Japan, Ministry of Foreign Affair
( 6) Department of Meteorology 2003

[ អាស័យដ្ឋានទាក់ទង ]


**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា**

#៤៤០A + ៤៤៨, មហាវិថីព្រះមុនីវង្ស ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
P.O. Box 613; Tel: 855-(0)23 212 142 /23 211 673/4; Fax: 855-(0)23 211 675 / 855-(0)15 913 639
Email: jica@online.com.kh ✭ Website: http://www.jica.go.jp/cambodia/english/